សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the
Promotion and Defense of
Human Rights



# ការបដិសេធសិទ្ធិបោះឆ្នោត៖

## ការបន្លំ ភាពមិនប្រក្រតី និងការគំរាមកំហែង នៅក្នុងអំឡុងពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣

របាយការណ៍ សង្ខេប
ចេញផ្សាយ ខែសីហា ឆ្នាំ២០១៣

# ការបដិសេធ សិទ្ធិបោះឆ្នោត៖

## ការបន្លំ ភាពមិនប្រក្រតី និងការគំរាមកំហែង នៅក្នុងអំឡុងពេល បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣

របាយការណ៍ចេញខែសីហា ឆ្នាំ២០១៣


**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស  លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តិ ដោយអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ**

បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**

ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**

អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានាៈ**

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ**

អ្នកហ្វឹកហ្វឺន និងអ្នកទាក់ទាញមតិគាំទ្រ ធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្តាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្តូរសង្គម និងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍ៈ**

ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ពត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


សេចក្ដីសង្ខេប ទំព័រ១

ប្រវត្តិ ទំព័រ២

ការស្វែងយល់បឋមអំពីច្បាប់បោះឆ្នោត ទំព័រ៣

ការបដិសេធសិទ្ធិបោះឆ្នោត ទំព័រ៥

មណ្ឌលបោះឆ្នោតវិទ្យាល័យវត្តភ្នំ រាជធានីភ្នំពេញ ទំព័រ៥
មណ្ឌលបោះឆ្នោត វត្តច្បារអំពៅ រាជធានីភ្នំពេញ ទំព័រ៥
មណ្ឌលបោះឆ្នោតសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទំព័រ៥
មណ្ឌលបោះឆ្នោត អនុវិទ្យាល័យអនុវត្តន៍ សង្កាត់ទឹកល្អក់៣ រាជធានីភ្នំពេញ ទំព័រ៦
មណ្ឌលបោះឆ្នោត សង្កាត់វិទ្យាល័យ ស្ទឹងមានជ័យ រាជធានីភ្នំពេញ ទំព័រ៦
ខេត្តកំពង់ចាម ទំព័រ៦
ខេត្តព្រះសីហនុ ទំព័រ៧
ឃុំសណ្ដាន់ស្រុកសណ្ដាន់ខេត្តកំពង់ធំ ទំព័រ៧
ខេត្តព្រៃវែង ទំព័រ៧
មណ្ឌលបោះឆ្នោត វិទ្យាល័យព្រៃថ្នង ទំព័រ៧
ស្រុកទឹកឈូ ខេត្តកំពត ទំព័រ៧
ស្រុកឧត្ដុង្គ ខេត្តកំពង់ស្ពឺ ទំព័រ៧
មណ្ឌលបោះឆ្នោត វត្តដំបូកខ្ពស់ រាជធានីភ្នំពេញ ទំព័រ៧
មណ្ឌលបោះឆ្នោត វិទ្យាល័យបាក់ទូក រាជធានីភ្នំពេញ ទំព័រ៧

ការបន្លំ និងការបោះឆ្នោតមិនសុចរិត ទំព័រ៨

មណ្ឌលបោះឆ្នោត សាលាបឋមសិក្សាដំរីឆ្លង ឃុំស្អាង ខេត្តកណ្ដាល ទំព័រ៨
សាលារៀនពាមសាលា ឃុំស្អាងភ្នំ ខេត្តកណ្ដាល ទំព័រ៩
ឃុំរីករាយ ស្រុករវៀង ខេត្តព្រះវិហារ ទំព័រ១០
ក្បួនរថយន្តទំនើបៗ បានដឹកជញ្ជូនមនុស្សមួយក្រុមធំ ដើម្បីមកបោះឆ្នោតនៅស្រុកកៀនស្វាយ ខេត្តកណ្ដាល ទំព័រ១០
អ្នកបោះឆ្នោតមួយក្រុមបានត្រលប់ទៅវិញ ដោយមិនបានបោះឆ្នោត ដោយសារប្រជាពលរដ្ឋ ក្នុងសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល បានធ្វើការរារាំង ទំព័រ១០
កងកម្លាំងប្រដាប់អាវុធជាច្រើននាក់ បានធ្វើដំណើរជាច្រើនក្រុមធំៗ ដើម្បីទៅបោះឆ្នោតនៅភាគខាងជើងខេត្តសៀមរាប ទំព័រ១១
និស្សិតសាកលវិទ្យាល័យចេនឡាជាច្រើនរយនាក់ត្រូវបានបញ្ជូនទៅបោះឆ្នោតនៅស្រុកល្វាឯមខេត្តកណ្ដាល ទំព័រ១១
ប្រជាពលរដ្ឋប្រមូលផ្ដុំគ្នាដើម្បីជំទាស់ជាមួយក្រុមអ្នកបោះឆ្នោតមួយក្រុមធំ ដែលមានសិទ្ធិបោះឆ្នោត ទំព័រ១២
នៅវត្តព្រៃតូច ក្នុង ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល ទំព័រ១៣

ការគំរាមកំហែង ទំព័រ១៤

ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្ដាល ទំព័រ១៤
ខេត្តកំពង់ចាម ទំព័រ១៤
ឃុំតាកុង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ទំព័រ១៤
ការគំរាមកំហែង ដោយវត្តមានរបស់អាជ្ញាធរក្នុងតំបន់ និង មន្ត្រីគណបក្សមួយចំនួន ទំព័រ១៤

យោបល់មួយចំនួន ទំព័រ១៤



# ការបន្លំ ភាពមិនប្រក្រតី និងការគំរាមកំហែង នៅក្នុងអំឡុងពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ប្រជាពលរដ្ឋកម្ពុជារាប់លាននាក់បានធ្វើដំណើរទៅកាន់មណ្ឌលបោះឆ្នោតប្រកបដោយឆន្ទៈក្នុងការគូសសន្លឹកឆ្នោត នៅក្នុងប្រទេសមួយដែលមានការប្រកួតប្រជែងយ៉ាងក្តៅគគុកក្នុងការបោះឆ្នោតសភាជាតិនេះ។ ប៉ុន្តែប្រជាពលរដ្ឋជាច្រើន ត្រូវបានខកខានមិនបានបោះឆ្នោតទៅវិញ ដោយពុំមានហេតុផលសមរម្យសោះ។ បញ្ហានេះ អ្នកសង្កេតការណ៍ ដែលត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (និកហ្វិច) ក៏បានកត់ត្រានូវបញ្ហា ភាពមិនប្រក្រតី ដែលគួរឲ្យព្រួយបារម្ភមួយចំនួន ដោយក្នុងចំណោមបញ្ហាទាំងនោះ បញ្ហាខ្លះបង្ហាញឲ្យឃើញនូវការប្រើប្រាស់ការបន្លំ និងការបោះឆ្នោតមិនសុច្ចរិត។ ជាលទ្ធផលពីការរកឃើញនូវបញ្ហាទាំងនេះ ដែលត្រូវបានរៀបរាប់នៅក្នុងរបាយការណ៍នេះ អង្គការលីកាដូសូមគាំទ្រ ដល់ការអំពាវនាវឲ្យមានការស៊ើបអង្កេតឯករាជ្យពិតប្រាកដ និងការរាប់សន្លឹកឆ្នោតនៅតាមមណ្ឌលបោះឆ្នោតឡើងវិញ ដោយមានអ្នកសង្កេតការណ៍ឯករាជ្យ មុននឹងសរុបលទ្ធផលចុងក្រោយ។

## សេចក្តីសង្ខេប

របាយការណ៍នេះនឹងចងក្រងនូវលទ្ធផលពីអ្នកសង្កេតការណ៍ចំនួន១៧៣នាក់ ជាបុគ្គលិក និងដៃគូ ដែលបានចុះទៅសង្កេតការណ៍តាមមណ្ឌលបោះឆ្នោតជាង១00កន្លែង[១]។ នៅក្នុងប្រទេសកម្ពុជាមានមណ្ឌលបោះឆ្នោតចំនួន ១៩,00៩ មណ្ឌល។ ជាការពិត របាយការណ៍នេះ មិនមានបំណងក្នុងការវិភាគឲ្យបានលំអិតទៅលើភាពមិនប្រក្រតីនៅក្នុងថ្ងៃបោះឆ្នោតនោះទេ ប៉ុន្តែគឺជាការផ្តល់នូវរូបភាពមួយចំនួនដែលបង្ហាញអំពីតម្រូវការការស៊ើបអង្កេតបន្ថែម។

ជារួម អ្នកសង្កេតការណ៍ បានរកឃើញនូវភាពមិនប្រក្រតីធ្ងន់ធ្ងរមួយចំនួន ដែលស្ថិតក្នុងស្ថានភាពអាសន្ននៅតាមមណ្ឌលដែលអ្នកទាំងនោះបានឃ្លាំមើល។ បញ្ហាទាំងអស់ត្រូវបានចែកជា ៣ ក្រុមសំខាន់ៗគឺ៖ ទីមួយគឺ ភាពមិនប្រក្រតីលើបញ្ជីឈ្មោះអ្នកបោះឆ្នោតរួមមាន ការបាត់ឈ្មោះដោយមិនមានមូលហេតុ និងការបដិសេធសិទ្ធិបោះឆ្នោត។ ទីពីរ គឺការបង្ហាញឲ្យឃើញពីបំណងក្នុងការបន្លំសន្លឹកឆ្នោត និង ទីបី គឺការគម្រាមកំហែង និងការរំខាន។

[១] អង្គការដៃគូរួមមានអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO), អង្គការអនាគតយុវជនកម្ពុជាអាស៊ាន (CamASEAN), ក្រុមការពារកុមារ (CPG), បណ្តាញកសាង សន្តិភាពសហគមន៍ (CPN), លីកាដូ កាណាដា, ក្រុមនាំសារ (MB), សមាគមធាងត្នោត (STT)

នៅក្នុងមណ្ឌលភាគច្រើនដែលបានសង្កេត អ្នកសង្កេតការណ៍របស់អង្គការលីកាដូ បានធ្វើការសាកសួរអ្នកបោះឆ្នោតមួយចំនួនដែលបានបាត់ឈ្មោះពីបញ្ជីឈ្មោះបោះឆ្នោត។ ពួកគេបានអះអាងថាធ្លាប់បានទៅពិនិត្យឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត និងឃើញឈ្មោះរបស់ខ្លួននៅក្នុងបញ្ជីឈ្មោះនៅមុនថ្ងៃបោះឆ្នោតម្តងរួចហើយ។ ដូចគ្នានេះដែរ អ្នកបោះឆ្នោតមួយចំនួន បានត្រលប់ទៅផ្ទះវិញ បន្ទាប់ពីត្រូវបានគេប្រាប់ថា មានអ្នកមកបោះដោយប្រើឈ្មោះអ្នកទាំងនោះ រួចទៅហើយ (ជារឿយៗ អ្នកដែលមកបោះឆ្នោតពីព្រលឹម បានប្រើប្រាស់ប័ណ្ណសម្គាល់អត្តសញ្ញាណសម្រាប់បោះឆ្នោត (ICE) ដែលចេញដោយមេឃុំ ជំនួសអត្តសញ្ញាណប័ណ្ណដែលមានរូប)។ អ្នកបោះឆ្នោតក៏ត្រូវបានបដិសេធសិទ្ធិរបស់អ្នកទាំងនោះ ក្នុងការបោះឆ្នោតដោយមិនមានមូលហេតុត្រឹមត្រូវ ដូចជាគ្រាន់តែអ្នកទាំងនោះមិនបានយកមកជាមួយនូវប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ទៅមណ្ឌលបោះឆ្នោត។

ប្រហែលជាស្ថានភាពគួរឲ្យភ្ញាក់ផ្អើល អ្នកសង្កេតការណ៍របស់អង្គការលីកាដូ បានរកឃើញថាបញ្ជីឈ្មោះអ្នកបោះឆ្នោតជាច្រើននៅក្នុងមណ្ឌលបោះឆ្នោតមួយចំនួនដែលបានសង្កេតការណ៍ ត្រូវបានគេកែប្រែដោយចេតនា។ នៅក្នុងករណីមួយ អ្នកសង្កេតការណ៍របស់អង្គការលីកាដូ បានសាកសួរអ្នកបោះឆ្នោតមួយចំនួន ដែលអ្នកទាំងនោះបានទទួលស្គាល់ថាពួកគេ ជាផ្នែកមួយនៃក្រុមធំដែលត្រូវបាននាំមកពីតំបន់ផ្សេងដោយនិយោជិតរបស់អ្នកទាំងនោះ ដើម្បីមកបោះឆ្នោតនៅក្នុងឃុំ ក្នុងតំបន់នេះ ទោះបីជាការពិតអ្នកទាំងនោះមិនបានចុះឈ្មោះបោះឆ្នោត ឬ មានលំនៅនៅក្នុងឃុំក្នុងតំបន់នេះក៏ដោយ។ អ្នកសង្កេតការណ៍របស់អង្គការលីកាដូ ក៏បានសង្កេតឃើញបុគ្គលមួយក្រុមដែលមានសំលៀកបំពាក់ស្អាតបាទ មកដល់មណ្ឌលបោះឆ្នោតដោយជិះរថយន្តទំនើប។ នៅក្នុងករណីនេះ ប្រជាពលរដ្ឋនៅក្នុងឃុំនេះ បានប្រាប់អ្នកសង្កេតការណ៍អង្គការលីកាដូ ថា បុគ្គលទាំងនោះមិនមែនរស់នៅក្នុងឃុំនេះទេ។ ជាចុងក្រោយនៅក្នុងខេត្តសៀមរាប អ្នកសង្កេតការណ៍អង្គការលីកាដូ បានឃើញទាហានយោធាចល័តមកកាន់មណ្ឌលបោះឆ្នោតថ្មីៗមួយចំនួនដើម្បីបោះឆ្នោត (ទាហានទាំងនោះបានធ្វើដំណើរមកពីខេត្តឧត្តរមានជ័យ និងព្រះវិហារ ហើយបានស្នាក់នៅវត្តក្បែរនោះ មុនពេលមកដល់ការិយាល័យបោះឆ្នោត)។ គ្រប់ករណីសិក្សាទាំងនេះ ត្រូវបានពិពណ៌នាលំអិតនៅចំនុចខាងក្រោម។

អង្គការលីកាដូ បានសង្កេតឃើញថា មានករណីនៃការគំរាមកំហែងជាច្រើន។ ករណីខ្លះ អ្នកសង្កេតការណ៍មួយចំនួន បានដឹងពីប្រជាពលរដ្ឋមួយចំនួន ដែលត្រូវបានគំរាមកំហែងរំខាន ដោយសារវត្តមានរបស់មន្ត្រីគណបក្សមួយចំនួន និងអាជ្ញាធរក្នុងឃុំ នៅក្នុងមណ្ឌលបោះឆ្នោត។ នៅក្នុងពេលនោះ អាជ្ញាធរទាំងនោះ បានធ្វើការកត់សម្គាល់លើអ្នកដែលបានទៅបោះឆ្នោត។ នៅខេត្តកំពង់ចាម អ្នកសង្កេតការណ៍របស់អង្គការលីកាដូ ត្រូវបានគេសាកសួរនៅយប់មុនថ្ងៃបោះឆ្នោត។ អ្នកសង្កេតការណ៍អង្គការលីកាដូជាច្រើន ក៏បានឃើញហេតុការណ៍នៃក្រុមប្រជាពលរដ្ឋនៅតាមមណ្ឌលបោះឆ្នោតជាក់លាក់មួយចំនួន បានធ្វើការរារាំងបុគ្គលមួយចំនួនមិនឲ្យបោះឆ្នោត ដោយផ្អែកលើជាតិសាសន៍របស់អ្នកទាំងនោះ។ ការរើសអើងនេះ រឹតតែទាមទារឲ្យមានការស៊ើបអង្កេតបន្ថែមទៅលើការបោះឆ្នោត។

ទោះបីជាអង្គការលីកាដូ ត្រឹមតែអាចធ្វើការសង្កេតការណ៍នៅតាមមណ្ឌលបោះឆ្នោតមួយចំនួនតូច ដោយមិនអាចធ្វើការចុះទៅសង្កេតការណ៍គ្រប់មណ្ឌលទាំងអស់ នៅក្នុងប្រទេសនៅក្នុងថ្ងៃបោះឆ្នោតក៏ដោយ ក៏ការសង្កេតការណ៍ខាងក្រោមទាំងនេះ បង្ហាញយ៉ាងច្បាស់នូវតម្រូវការក្នុងការស៊ើបអង្កេតឲ្យបានស៊ីជម្រៅបន្ថែមទៀត និងនីតិវិធីបន្ថែមទៀត មុនពេលសម្រេចលទ្ធផលបោះឆ្នោតជាផ្លូវការចុងក្រោយ។

# ប្រវត្តិ

ប្រវត្តិនៃបញ្ហាជាក់លាក់មួយចំនួន នៅជុំវិញការបោះឆ្នោត គួរតែត្រូវបានពិចារណា មុនពេលលទ្ធផលនៃការសង្កេតការណ៍នៅថ្ងៃបោះឆ្នោតត្រូវបានពិពណ៌នា។

នៅពេលយប់ក្នុងថ្ងៃបោះឆ្នោត ស្ថានីយ៍ទូរទស្សន៍ជាតិ ទទក[២] បានចាប់ផ្តើមប្រកាសលទ្ធផលតាមឃុំនីមួយៗ។ នៅពេលកំពុងផ្សាយនោះ ស្រាប់តែមានការឈប់ផ្សាយភ្លាម ហើយបែរជាចាក់ផ្សាយបទចំរៀងវីដេអូទៅវិញ។ នៅពេលដែលបន្តផ្សាយលទ្ធផលតទៅទៀត អ្នកប្រកាសបាននិយាយដោយប្រញាប់ថា មិនអាចប្រកាសតាមឃុំនីមួយៗ បានទៀតឡើយ ប៉ុន្តែអានជាសរុប តាមខេត្តនីមួយៗទៅវិញតែម្តង[៣]។ ម៉្យាងវិញទៀត ពិធីករបានអានលទ្ធផលឆ្នោតសរុបក្នុងខេត្តនីមួយៗ ប៉ុន្តែបានធ្វើការកត់សំគាល់ថាខេត្តខ្លះមិនទាន់មានលទ្ធផលពីគ្រប់ការិយាល័យបោះឆ្នោតនៅឡើយ ដែលនេះមិនទាន់ពេញលេញនោះទេ។ រហូតដល់រយៈពេលជិត៣សប្តាហ៍កន្លងទៅហើយ លទ្ធផលតាមឃុំនិមួយៗ នៅតែមិនទាន់ទទួលបានទៀត។ ជាថ្មីម្តងទៀត លទ្ធផលបឋម របស់គណៈកម្មាធិកាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសផ្សាយកាលពីថ្ងៃទី១២ ខែសីហា កន្លងទៅនេះ គឺជាលទ្ធផល តាមខេត្តនីមួយៗដដែល។

នេះជាអ្វីមួយ ដែលខុសទាំងស្រុងពីការបោះឆ្នោតជាតិឆ្នាំ២០០៨ ដែលនៅពេលនោះ គ.ជ.ប បានប្រកាសលទ្ធផលតាមការិយាល័យនីមួយៗ។ ការបដិសេធ មិនប្រកាសតួលេខជាក់លាក់សម្រាប់ការបោះឆ្នោតនេះ គឺមិនមានលក្ខណៈ ត្រឹមត្រូវនោះទេ។ ការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យនីមួយៗ សុទ្ធតែមានអ្នកសង្កេតការណ៍របស់គណបក្ស ហើយមានករណីជាច្រើន ក៏ត្រូវបានចូលរួមសង្កេត-ការណ៍ដោយអ្នកសង្កេតការណ៍ឯករាជ្យថែមទៀតផង។ លទ្ធផលនៃការរាប់នោះ ត្រូវបានកត់ត្រាទុកនៅក្នុងទម្រង់១១០២ (ទម្រង់ឯកសារផ្លូវការមួយ ដែលបន្ទាប់មក ត្រូវបានអ្នកសង្កេតការណ៍ចុះហត្ថលេខាទទួលស្គាល់ទាំងអស់គ្នា)។ បន្ទាប់មកទម្រង់ទាំងនោះ នឹងត្រូវបានផ្ញើទៅកាន់ថ្នាក់ឃុំ ដែលនៅទីនោះគេនឹង ធ្វើ ការសរុបរួចបញ្ចូលទៅក្នុងទម្រង់ ១១០៩។ ការបញ្ជូន និងនីតិវិធីនេះ គឺមិនមានការសង្កេតការណ៍ឯករាជ្យនោះឡើយ ដូច្នេះការរាប់នេះមិនអាចជឿជាក់បាន ដូចការរាប់នៅតាមការិយាល័យនីមួយៗឡើយ។

លើសពីនេះ លទ្ធផលជាបឋម ដែលប្រកាសដោយ គ.ជ.ប នៅ

[២] ស្ថានីយ៍ទូរទស្សន៍នៅក្នុងប្រទេសកម្ពុជា គឺត្រូវបានគ្រប់គ្រងដោយបុគ្គលដែលជិតស្និតនឹងគណបក្សកាន់អំណាច ដែលរួមមានទាំងកូនរបស់នាយករដ្ឋមន្ត្រី
[៣] http://www.youtube.com/watch?v=0Nlgx5hWLwo

ថ្ងៃទី១២ ខែសីហា បានបង្ហាញឲ្យឃើញថាមានលទ្ធផលខុសគ្នានៅទូទាំងប្រទេស រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិស្មើនឹង២៨៩,៧៩៣សំលេង(ជាគម្លាតតូចមួយដែលគិតទៅត្រឹមតែ ច្រើនជាង៤ ភាគរយ បន្តិច នៃចំនួនសរុបតែប៉ុណ្ណោះ)។ ដោយសារគម្លាតដ៏តិចតួចនេះហើយ ទើបគេគួរតែធ្វើការរាប់សន្លឹកឆ្នោតតាមមណ្ឌលនីមួយៗម្តងទៀត ទោះបីជាមិនមានបណ្តឹង អំពីភាពមិនប្រក្រតីក្នុងការបោះឆ្នោតក៏ដោយ។ ហើយការរាប់តាមណ្ឌលជាថ្មីនេះមិនទាន់ត្រូវបានធ្វើឡើងវិញនៅឡើយទេ។

តាមតួរលេខរបស់ គ.ជ.ប បានបង្ហាញឲ្យឃើញដូចខាងក្រោមៈ

► នៅក្នុងបញ្ជីអ្នកបោះឆ្នោត មានចំនួនមនុស្សច្រើនជាង ២៧០,០០០នាក់ មានឈ្មោះដូចគ្នាបេះបិទតែម្តង (ដូចទាំងថ្ងៃ ខែ ឆ្នាំ កំណើត និងព័ត៌មានផ្សេងទៀតនៅក្នុងអត្តសញ្ញាណប័ណ្ណ)។

► ចំនួនទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណបោះឆ្នោត ចំនួនជាង ៤៨០,០០០ សន្លឹក ត្រូវបានចេញសំរាប់ការបោះឆ្នោតនេះ។

► ឈ្មោះអ្នកបោះឆ្នោតប្រហែល ២៩០,០០០នាក់ ត្រូវបានបាត់ពីបញ្ជីបោះឆ្នោត ដែលមានការខុសគ្នាយ៉ាងច្រើន នៅពេលដែលធ្វើការប្រៀបធៀបនឹងការប៉ាន់ប្រមាណ ដែលត្រូវបានគណនាដោយក្រុមសង្កេតការណ៍ឯករាជ្យទាំងអស់។

ការប៉ាន់ប្រមាណពីដើមនេះ បង្ហាញឲ្យឃើញ អំពីសារៈសំខាន់ក្នុងការស៊ើបអង្កេត ដែលមានលក្ខណៈឯករាជ្យមួយ ចំពោះភាពមិនប្រក្រតីដែលស្តែងចេញពីការបោះឆ្នោតនេះ។ ចុះប្រសិនបើត្រឹមតែ ២០ភាគរយ នៃតួលេខ ដែលទទួលស្គាល់ដោយ គ.ជ.ប ខាងលើ គឺជាចំនួនមួយដែលមានចេតនាបន្លំ នោះវានឹងធ្វើឲ្យមានការប៉ះពាល់ដល់កម្រិតជោគជ័យ ក្នុងលទ្ធផលបោះឆ្នោតទៅហើយ។

ការធ្វើសវនកម្មឯករាជ្យមួយ លើចំនួនអ្នកបោះឆ្នោត ៤,៩០០នាក់ ដែលធ្វើឡើង ក្នុងឆ្នាំ២០១៣ ក៏បានរកឃើញផងដែរថា ១០,៤ ភាគរយ នៃឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត គឺជាឈ្មោះដែលគ្មានមនុស្សហើយទន្ទឹមនឹងនោះ ឈ្មោះអ្នកបោះឆ្នោត ដែលធ្លាប់មានពីមុនចំនួន ៩,៤ភាគរយ ត្រូវបានលុបចេញពីបញ្ជីដោយអយុត្តិធម៌។ ការធ្វើសវនកម្មនេះ ត្រូវបានធ្វើឡើង ដោយវិទ្យាស្ថានប្រជាធិបតេយ្យជាតិ (NDI) និង គណៈកម្មាធិការដើម្បីការបោះឆ្នោតសេរី និងយុត្តិធម៌នៅកម្ពុជា (និកហ្វិក) ហើយការត្រួតពិនិត្យនោះ ត្រូវបានធ្វើឡើងដើម្បីសម្រាប់អ្នកបោះឆ្នោតនៅក្នុងខេត្តចំនួន ២៤ ខេត្ត-ក្រុង។ នៅក្នុងការបោះឆ្នោត ឆ្នាំ២០០៨ មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ត្រឹមតែ ៧,៧ ភាគរយ តែប៉ុណ្ណោះ ដែលត្រូវបានរកឃើញថា ឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត មិនត្រូវជាមួយមនុស្សពិត។ តាមការធ្វើសវនកម្មនោះ ក៏បានរកឃើញផងដែរ ដោយថ្ងៃ ខែ ឆ្នាំ កំណើតនៃអ្នកបោះឆ្នោតត្រឹមតែ ៦៣ ភាគរយ ប៉ុណ្ណោះ ផ្ទៀងផ្ទាត់ត្រឹមត្រូវក្នុងបញ្ជីបោះឆ្នោត ហើយប្រសិនបើប្រៀបធៀបជាមួយការបោះឆ្នោត ឆ្នាំ២០០៨ ឃើញថា ថ្ងៃ ខែ ឆ្នាំ កំណើត ដែលផ្ទៀងផ្ទាត់ត្រឹមត្រូវនេះ មានរហូតដល់ ៧៨,៩៧ ភាគរយ។ បញ្ហានេះតែមួយគត់ អាចនាំឲ្យអ្នកបោះឆ្នោត រាប់រយពាន់នាក់បានបាត់ឈ្មោះពីបញ្ជី។ តួលេខទាំងនេះ មានបញ្ហាទ្វេដង នៅពេលធ្វើការពិចារណាទៅលើតំបន់ភាគច្រើន ដែលមានឈ្មោះអ្នកបោះឆ្នោតច្រើនជាងប្រជាពលរដ្ឋដែលរស់នៅ។

ជាចុងក្រោយ គ្រាន់តែ ២៤ ម៉ោង មុនពេលបោះឆ្នោត គ.ជ.ប បានដកបញ្ជីឈ្មោះអ្នកបោះឆ្នោត ចេញពីគេហទំព័ររបស់ខ្លួន ដោយ



អ្នកបោះឆ្នោតកំពុងផ្ទៀងផ្ទាត់ឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតនៅក្នុងខេត្តកណ្តាល ក្នុងអំឡុងពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០១២

និយាយថា មិនចង់ឲ្យគណៈបក្សនយោបាយនានា "កេងយក" ចំណេញពីបញ្ជីនេះ។ បន្ទាប់មក មួយជំហានទៀត គ.ជ.ប បានចេញសេចក្តីជូនដំណឹងមួយថា ឯកសារបញ្ជីឈ្មោះបោះឆ្នោត ដែលបោះពុម្ពចេញមុនពេលបញ្ជីនោះត្រូវបានដកចេញពីគេហទំព័រត្រូវហាមប្រើនៅក្នុងមណ្ឌលបោះឆ្នោត ពីព្រោះវាអាចធ្វើ "ឲ្យមានការភាន់ច្រឡំ"។ ចំណុចនេះ គឺមានការលំបាកយល់ ជាពិសេសដោយមានភាពខុសគ្នារវាងបញ្ជីឈ្មោះនៅក្នុងគេហទំព័រ ដែលប្រជាពលរដ្ឋធ្លាប់ពឹងផ្អែកក្នុងការរកមណ្ឌលបោះឆ្នោត និងផ្ទៀតផ្ទាត់មើលឈ្មោះរបស់ខ្លួន និងបញ្ជីឈ្មោះ ដែលត្រូវបានបិទនៅតាមមណ្ឌលបោះឆ្នោត នីមួយៗ។

## ការស្វែងយល់បឋមអំពីច្បាប់បោះឆ្នោត

សេចក្តីសង្ខេប អំពីលក្ខខណ្ឌតំរូវ នៃអ្នកចុះឈ្មោះបោះឆ្នោតនៃប្រទេសនេះ នៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺ មានសារៈប្រយោជន៍ ក្នុងការស្វែងយល់អំពីការអះអាងនៃភាពមិនប្រក្រតីឲ្យបានលំអិតតាមរយៈរបាយការណ៍នេះ។

បញ្ជីឈ្មោះអ្នកបោះឆ្នោត គឺត្រូវបានពិនិត្យឡើងវិញ និងកែលម្អ

ជារៀងរាល់ឆ្នាំចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ។[៤] ការចុះឈ្មោះ និងការកែលម្អបញ្ជីឈ្មោះបោះឆ្នោត ត្រូវបានធ្វើឡើងនៅថ្នាក់ឃុំ។[៥]

ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចបោះឆ្នោតបាន ឈ្មោះរបស់ពលរដ្ឋត្រូវតែមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ហើយពលរដ្ឋម្នាក់ៗ ត្រូវតែមានឯកសារសំគាល់អត្តសញ្ញាណដែលបានកំណត់នៅជាប់ខ្លួនក្នុងអំឡុងពេលបោះឆ្នោត[៦]។ អ្នកបោះឆ្នោតមិនតំរូវឲ្យយកប័ណ្ណព័ត៌មានបោះឆ្នោតក្នុងពេលទៅបោះឆ្នោតនោះទេ ប៉ុន្តែផ្ទុយទៅវិញ ព័ត៌មានជាច្រើន ដែលទទួលបានបញ្ជាក់ថាពលរដ្ឋមួយចំនួនត្រូវបានគេបដិសេធមិនឲ្យមានសិទ្ធិបោះឆ្នោតទៅវិញ ប្រសិនបើមិនយកប័ណ្ណព័ត៌មានទៅជាមួយក្នុងថ្ងៃបោះឆ្នោត។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក៏បានលើកឡើងអំពីឯកសារមួយចំនួន ដែលអាចបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកបោះឆ្នោត ហើយក្នុងចំណោមឯកសារទាំងនោះ មានមួយ គឺជាលិខិតបញ្ជាក់ដែលចេញដោយមេឃុំដែលអាចយកទៅប្រើប្រាស់បានក្នុងករណីដែលជនណាម្នាក់ ពុំមានឯកសារផ្លូវការណាផ្សេងទៀត។ លិខិតបញ្ជាក់នេះ គឺសំដៅទៅលើទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោត (ICE)។ ការចេញនូវទម្រង់នេះ នៅថ្នាក់មូលដ្ឋានដោយមន្ត្រីរបស់គណបក្សដែលបានជាប់ឆ្នោត ដោយមានការដឹងឮ ឬ ឃ្លាំមើលតិចតួចបំផុត គឺពោរពេញទៅដោយបញ្ហា។ លើសពីនេះទៅទៀត មន្ត្រីឃុំជាច្រើន តម្រូវឲ្យឈប់ផ្តល់ទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោតនេះត្រឹមថ្ងៃទី១២ ខែកក្កដា។

ដើម្បីចុះឈ្មោះបោះឆ្នោតបាន បុគ្គលម្នាក់ៗត្រូវតែជាពលរដ្ឋខ្មែរ ហើយមានអាយុលើសពី១៨ឆ្នាំ ព្រមទាំងត្រូវមានទីលំនៅនៅក្នុងឃុំដែលជននោះនឹងត្រូវទៅបោះឆ្នោត[៧]។ ពលរដ្ឋខ្មែរម្នាក់ៗអាចចុះឈ្មោះបោះឆ្នោតបានតែឈ្មោះមួយ និងតែមួយកន្លែងគត់[៨]។ ដំណើរការនៃការចុះឈ្មោះបោះឆ្នោត ត្រូវបានរៀបរាប់លំអិត នៅក្នុងមាត្រា ៥៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានចែងផង ដែរថា នៅពេលដែលពលរដ្ឋណាម្នាក់បានចុះឈ្មោះត្រឹមត្រូវរួចហើយនៅឃុំរបស់ខ្លួន នោះឈ្មោះរបស់បុគ្គលនោះ ត្រូវតែនៅមានជារៀងរហូត លុះត្រាតែពេលណាមួយដែលពលរដ្ឋនោះឈប់រស់នៅក្នុងឃុំនោះទៀត ហើយបានចុះឈ្មោះនៅកន្លែងផ្សេងវិញ ឬ ពលរដ្ឋនោះ បានទទួលមរណៈភាព ឬ ក្លាយជាពលរដ្ឋដែលមិនអាចបោះឆ្នោតបាន ដូចជា ជាប់ពន្ធនាគារជាដើម។ ជាការពិត ការអះអាងពីសំណាក់អ្នកសង្កេតការណ៍មួយចំនួនថា មន្ត្រីមួយចំនួនបានប្រាប់អ្នកបោះឆ្នោតថា ឈ្មោះរបស់អ្នកទាំងនោះ ត្រូវបានលប់ចេញពីបញ្ជីបោះឆ្នោតបាត់ទៅហើយ ដោយសារតែអ្នកទាំងនោះមិនបានមកចុះឈ្មោះសារជាថ្មី នោះពុំមែនជាសកម្មភាពស្របតាមច្បាប់ទេ។

លក្ខខណ្ឌតំរូវលំអិតទាំងនេះ ព្រមទាំងការវាយតម្លៃឡើងវិញនូវបញ្ជីឈ្មោះអ្នកបោះឆ្នោតប្រចាំឆ្នាំបាន នាំឲ្យមានការចោទជាសំនួរថែមទៀត អំពីបញ្ហានៃការចុះឈ្មោះអ្នកបោះឆ្នោត លើសចំនួនប្រជាពលរដ្ឋពិតប្រាកដ[៩] ដែលត្រូវបានគេរាយការណ៍ជាច្រើន។ ជាការពិតភាគច្រើន (ប្រសិនបើមិនមានភាគច្រើនលើសលុប) នៃភាពមិនប្រក្រតី ដែលបានរៀបរាប់ក្នុងរបាយការណ៍នេះ គឺបានមកពីការសង្កេតការណ៍ នៅក្នុងតំបន់ដែលបញ្ជីឈ្មោះអ្នកបោះឆ្នោត សុទ្ធតែមានចំនួនលើសពី ចំនួនប្រជាពលរដ្ឋជាក់ស្តែង រហូតដល់ជាង ១០០ ភាគរយ នៃចំនួនប្រជាពលរដ្ឋសរុប។

ការចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសបែបនេះ និងភាពមិនប្រក្រតីផ្សេងទៀតជាច្រើន គឺជាបញ្ហាប្រឈម ដោយសារជាក់ស្តែងចំនួនអសនៈសម្រាប់តំណាងរាស្ត្រនៅក្នុងប្រទេសកម្ពុជា ត្រូវបានបែងចែកតាមខេត្តនីមួយៗ ទៅតាមរូបមន្ត ដែលបានចែងនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ជាឧទាហរណ៍ ខេត្តកំពង់ស្ពឺ មានអសនៈចំនួន ៦ ដែលត្រូវបានបែងចែកអាស្រ័យដោយសំលេងអ្នកបោះឆ្នោតនៅខេត្តកំពង់ស្ពឺ តែប៉ុណ្ណោះ។ ការបែងចែងអសនៈតាមខេត្តនីមួយៗនេះ មានន័យថា ភាពមិនប្រក្រតីជាច្រើន ដែលកើតឡើងនៅក្នុងខេត្តដែលមានការប្រកួតប្រជែងប្រកៀកគ្នា នឹងមានការប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលសរុប។

[៤] មាត្រា ៤៩ នៃច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
[៥] មាត្រា ៥៣ នៃច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
[៦] មាត្រា ៥៣ នៃច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
[៧] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
[៨] មាត្រា ៦២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
[៩] "បញ្ជីអ្នកបោះឆ្នោតមានលើសពីចំនួនមនុស្សពិតប្រាកដ" ដោយលោក David Boyle, កាសែតភ្នំពេញប៉ុស្តិ៍, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ (ភាសាខ្មែរ)

# ការបដិសេធសិទ្ធិបោះឆ្នោត

នៅតាមមណ្ឌលបោះឆ្នោតជាច្រើនលើសលុប ដែលអ្នកសង្កេតការណ៍បោះឆ្នោត របស់អង្គការលីកាដូ បានធ្វើការសង្កេតការណ៍ មានបញ្ហាជាច្រើនត្រូវបានរកឃើញដូចជាបញ្ជីឈ្មោះបោះឆ្នោតមិនពេញលេញ និងភាពមិនប្រក្រតីដែលពាក់ព័ន្ធជាច្រើនទៀត។

## មណ្ឌលបោះឆ្នោតវិទ្យាល័យវត្តភ្នំ រាជធានីភ្នំពេញ

វិទ្យាល័យវត្តភ្នំ ស្ថិតក្នុងតំបន់ដែលអ្នកចុះឈ្មោះកើនដល់ ១៣៨,៦ ភាគរយ។ នៅក្នុងសាលានេះមានការិយាល័យបោះឆ្នោត ចំនួន ១៥ កន្លែង ហើយជាមណ្ឌលបោះឆ្នោតដ៏សំខាន់ សំរាប់ប្រជាពលរដ្ឋតំបន់បឹងកក់។

គ្រាន់តែការិយាល័យបោះឆ្នោតបើកភ្លាម អ្នកសង្កេតការណ៍អង្គការលីកាដូ ក៏ទទួលបានរបាយការណ៍ពីប្រជាពលរដ្ឋ ដែលពុំអាចបោះឆ្នោតបាន។ ចន្លោះម៉ោង ៧និង៣០ ព្រឹក ដល់ម៉ោង ១១ព្រឹក បណ្ដឹងចេះតែកើតមានជារៀងរហូត។

ខណៈដែលអ្នកសង្កេតការណ៍ ស្ថិតនៅក្នុងបរិវេណមណ្ឌលបោះឆ្នោតនៅឡើយ ពួកគេបានជួបពលរដ្ឋ ៧៧ នាក់ ដែលពុំអាចបោះឆ្នោតបាន ដោយមូលហេតុដូចខាងក្រោមៈ

► ១៦នាក់ មានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវនិង ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ប៉ុន្តែមិនអាចរកឈ្មោះឃើញនៅក្នុងបញ្ជី ក្នុងមណ្ឌលបោះឆ្នោត។

► ៣៩នាក់ មានអត្តសញ្ញាណប័ណ្ណ ប៉ុន្តែពុំមានប័ណ្ណព័ត៌មានអ្នកបោះឆ្នោតហើយក៏មិនអាចរកឈ្មោះឃើញក្នុងបញ្ជីដែរ (ពួកគេភាគច្រើន មានប័ណ្ណបោះឆ្នោតពីការបោះឆ្នោតឃុំ-សង្កាត់ កាលពីឆ្នាំកន្លងទៅ)

► ១៩នាក់ មានអត្តសញ្ញាណប័ណ្ណមិនត្រឹមត្រូវ

► ៣នាក់ ពេលមកដល់ការិយាល័យបោះឆ្នោតស្រាប់តែឈ្មោះរបស់ខ្លួនត្រូវបានគេបោះជំនួសរួចហើយ។
ព័ត៌មានលំអិតសំរាប់ករណី ទាំងនេះមានដូចខាងក្រោមៈ

នៅការិយាល័យបោះឆ្នោតលេខ០២៥២ បុរសម្នាក់[១០] មានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ ហើយឈ្មោះគាត់ឃើញមាននៅក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែត្រកូលរបស់គាត់ ត្រូវបានគេសរសេរខុសបន្តិច។ អាស័យដ្ឋាន និង ថ្ងៃខែឆ្នាំកំណើត ត្រឹមត្រូវ។ គេត្រូវបានប្រាប់គាត់ថា មានគេបោះឆ្នោតជំនួសគាត់រួចហើយ ដោយប្រើទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់អ្នកបោះឆ្នោត ដោយមាននាមត្រកូលខុសគ្នាបន្តិច ប៉ុន្តែព័ត៌មានផ្ទាល់ខ្លួនផ្សេងៗទៀតដូចគ្នាទាំងអស់។

ស្រដៀងគ្នានេះដែរ ស្ត្រីម្នាក់មានលិខិតឆ្លងដែន ហើយក៏អាចរកឈ្មោះឃើញនៅក្នុងបញ្ជីដែរ។ នាងបានបាត់អត្តសញ្ញាណប័ណ្ណព្រមទាំងបានរាយការណ៍ជូនអាជ្ញាធររួចហើយដែរ។ នាងត្រូវបានគេប្រាប់ថា មានគេយកឈ្មោះនាងបោះឆ្នោតរួចហើយ ដោយប្រើប្រាស់អត្តសញ្ញាណប័ណ្ណ និង ប័ណ្ណព័ត៌មានបោះឆ្នោត។

ស្ត្រីម្នាក់ទៀតក៏មានលិខិតឆ្លងដែនដែរ ហើយក៏ឃើញមាន



ស្ត្រីម្នាក់នេះ មិនត្រូវបានគេអនុញ្ញាតឲ្យបោះឆ្នោត ព្រោះមានបុរសម្នាក់បានបោះឆ្នោតដោយប្រើប្រាស់ឈ្មោះរបស់គាត់រួចទៅហើយ។

ឈ្មោះនៅក្នុងបញ្ជីដែរ ប៉ុន្តែនាងត្រូវបានគេប្រាប់ថា មានបុរសម្នាក់បានបោះឆ្នោតជំនួសរួចហើយ។ បុរសនោះ មានអត្តសញ្ញាណប័ណ្ណនិងអាសយដ្ឋានត្រឹមត្រូវ ព្រមទាំងប័ណ្ណព័ត៌មានអ្នកបោះឆ្នោតផង។ ពេលដែលបុរសនោះបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោតទើបតែកែតម្រូវភេទរបស់អ្នកបោះឆ្នោត នៅក្នុងបញ្ជីឈ្មោះ ពីភេទស្រី ទៅភេទប្រុសវិញប៉ុណ្ណោះ។

មន្ត្រីនៅក្នុងការិយាល័យបោះឆ្នោត ពុំបានជួយអ្វីទាល់តែសោះចំពោះពលរដ្ឋដែលមិនអាចបោះឆ្នោតទាំងនោះ ព្រមទាំងពុំមានទម្រង់បណ្ដឹងថែមទៀតផង។ នៅវេលាប្រហែលម៉ោង ១០និង៣០ ព្រឹក ទើបអ្នកសង្កេតការណ៍ម្នាក់មកពីអង្គការខុមហ្វ្រែល ជួយរកទម្រង់បណ្ដឹងរបស់គ.ជ.ប០១ច្បាប់ពីមន្ត្រីគ.ជ.ប។មន្ត្រីនោះក៏បានបញ្ជូនសហការីឲ្យទៅថតចម្លងជាច្រើនច្បាប់ ដែលចំណាយពេលអស់មួយរយៈធំ។

## មណ្ឌលបោះឆ្នោតវត្តច្បារអំពៅ រាជធានីភ្នំពេញ

អ្នកសង្កេតការណ៍អង្គការលីកាដូ ម្នាក់ បានរាយការណ៍ថា បានឃើញមានការចែកចាយ នូវទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសំរាប់អ្នកបោះឆ្នោត (ICE) នៅថ្ងៃបោះឆ្នោតនៅច្បារអំពៅ។ ការចែកចាយបែបនេះ គឺជាការអនុវត្តន៍ខុសច្បាប់ទាំងស្រុង។ អ្នកសង្កេតការណ៍ អង្គការលីកាដូ ក៏ត្រូវបានគេគំរាមកំហែងចាប់ខ្លួនពេលដែលគាត់ថតរូបពលរដ្ឋម្នាក់ ដែលអាចលុបលាងទឹកខ្មៅចេញពីម្រាមដៃរបស់គាត់បានយ៉ាងងាយបំផុតនោះ។ ចៅសង្កាត់ម្នាក់ បានគំរាមវាយដំ មកលើអ្នកសង្កេតការណ៍អង្គការ លីកាដូ។ មនុស្សមួយចំនួនដែលបានបង្ហាញនូវភាពងាយស្រួល ក្នុងការលាងទឹកខ្មៅចេញពី

[១០]ឈ្មោះត្រូវបានគេលុបចេញ

## ខេត្តកំពង់ចាម

នៅឃុំត្រពាំងគ អ្នកសង្កេតការណ៍អង្គការលីកាដូ បានឃើញមានការប្រើប្រាស់ទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត ចំនួនពី ១៥ ទៅ ២០សន្លឹក ត្រូវបានប្រើប្រាស់ក្នុងរយៈពេលតែ ១ម៉ោងប៉ុណ្ណោះ។

នៅឯមណ្ឌលបោះឆ្នោតសាលាបឋមសិក្សាវត្តដីដុត ក្នុងភូមិលេខ ២ សង្កាត់វាលវង់ អ្នកសង្កេតការណ៍ បានកត់សំគាល់ឃើញមនុស្សចំនួន ១៥នាក់ មិនអាចរកឈ្មោះឃើញនៅក្នុងបញ្ជីបោះឆ្នោត ហើយ ២០នាក់ ផ្សេងទៀតមានឈ្មោះស្ទួននៅមណ្ឌលផ្សេងទៀតផងដែរ។

នៅក្នុងការិយាល័យលេខ ១៦៩៦ ក្នុងឃុំស្រឡប់ ស្រុកត្បូងឃ្មុំ អ្នកសង្កេតការណ៍អង្គការលីកាដូ ត្រូវបានគេរាយការណ៍ប្រាប់ថា មួយថ្ងៃមុនថ្ងៃបោះឆ្នោត ក្រុមការងារគណបក្សកាន់អំណាច បានចែកលុយឲ្យអ្នកដែលធ្លាប់បោះឆ្នោតជូនគណបក្សកាន់អំណាច។ ហើយនៅក្នុងស្រុកនេះដែរក៏មានមនុស្សជាច្រើនដែលបានបាត់ឈ្មោះពីបញ្ជីដែរ ចាប់តាំងពីការបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំកន្លងទៅ។

ម្រាមដៃរបស់គាត់ គឺជាប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់នោះ ដែលកំពុងរាយការណ៍ប្រាប់ឲ្យអ្នកសង្កេតការណ៍បានដឹងអំពីការព្រួយបារម្ភរបស់អ្នកទាំងនោះ ប៉ុន្តែពួកគេមិនមានបំណងក្នុងការបោះឆ្នោត ច្រើនដងនោះទេ។

## មណ្ឌលបោះឆ្នោតសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

នៅការិយាល័យបោះឆ្នោតលេខ ០៦៣៣ មានពលរដ្ឋមួយចំនួនបាននិយាយថា ពួកគេបានពិនិត្យមើលឈ្មោះរបស់ខ្លួននៅក្នុងគេហទំព័ររបស់ គ.ជ.ប ប៉ុន្តែពួកគេមិនអាចរកឈ្មោះរបស់ខ្លួនឃើញនៅក្នុងបញ្ជីបោះឆ្នោតទៅវិញ។ ពួកគេក៏និយាយផងដែរថា ខាង គ.ជ.ប បានប្រើប្រាស់ខ្មៅដៃដែលអាចលប់បាន សំរាប់ឆូតឈ្មោះក្នុងបញ្ជីបោះឆ្នោត។ នេះប្រហែលជាអ្វី ដែលគួរភ្ញាក់ផ្អើលបំផុតនោះគឺ សាក្សីបានឃើញកូនប្រុសរបស់លោកមេភូមិបានដាក់សន្លឹកឆ្នោតជាច្រើនទៅក្នុងប្រអប់បោះឆ្នោតនៅវេលាម៉ោងប្រហែល ១២និង៥០នាទី។ អ្នកភូមិ ក៏បាននាំគ្នាស្រែកឲ្យចាប់គាត់ ប៉ុន្តែពុំមានអ្នកណាចាប់ទេ។ ហើយការិយាល័យលេខ ០៦២៨ អ្នកភូមិបាននិយាយថា ពួកគេបានឃើញគ្រូថ្នាក់ទី៧ ម្នាក់ បោះត្រាលើសន្លឹកឆ្នោតជាច្រើនហើយលាក់សន្លឹកឆ្នោតទាំងនោះនៅវេលាម៉ោង ១២និង២០នាទី។

## មណ្ឌលបោះឆ្នោតអនុវិទ្យាល័យអនុវត្តន៍ សង្កាត់ទឹកល្អក់៣រាជធានីភ្នំពេញ

ខណៈដែលអ្នកសង្កេតការណ៍ លីកាដូ មានវត្តមាននៅទីនោះ បុរស១នាក់ មិនត្រូវបានអនុញ្ញាតឲ្យបោះឆ្នោត ពីព្រោះមាននរណាម្នាក់ប្រើឈ្មោះគាត់បោះឆ្នោតរួចហើយ។ ក្នុងខណៈនោះផងដែរ ពលរដ្ឋ ១០នាក់ នៅឯការិយាល័យលេខ ០៤៤១ មិននឹកស្មានថាបាត់ឈ្មោះពីបញ្ជីបោះឆ្នោតទាល់តែសោះ ហើយត្រូវត្រឡប់ទៅផ្ទះវិញដោយពុំបានបោះឆ្នោត។

## មណ្ឌលបោះឆ្នោតសង្កាត់វិទ្យាល័យស្ទឹងមានជ័យ រាជធានីភ្នំពេញ

មហាជនយ៉ាងច្រើនកុះករ បានប្រមូលផ្តុំគ្នានៅមណ្ឌលបោះឆ្នោតនេះ ដោយសារការបាត់ឈ្មោះអ្នកបោះឆ្នោតជាច្រើនពីក្នុងបញ្ជី។ ភ្លាមៗនោះ មន្ត្រី គ.ជ.ប ឃុំ/សង្កាត់ បានបដិសេធជួយអ្នកដែលមិនបានបោះឆ្នោតទាំងនោះ ហើយបែរជាប្រាប់អ្នកទាំងនោះឲ្យត្រឡប់ទៅផ្ទះវិញ។ ភាពតានតឹង រឹតតែមានសភាពខ្លាំងឡើងៗ។



នគរបាលបានអន្តរាគមន៍ក្នុងស្ថានភាពចលាចល ដោយសារការបាត់ឈ្មោះជាច្រើននៅស្ទឹងមានជ័យ

ពាក្យចចាមអារាមទាក់ទងនឹងព្រះសង្ឃ ដែលកំពុងត្រូវបានអ្នកកាសែតសម្ភាសន៍អំពីការបាត់ឈ្មោះអ្នកបោះឆ្នោត ត្រូវបានគេវាយដំ បានចាប់ផ្តើមឡើង។ អ្នកនៅក្បែរកន្លែងកើតហេតុ បានអះអាងថាស្គាល់បុគ្គលដែលបានវាយដំលើព្រះសង្ឃនោះ ដោយបានចង្អុលទៅអាជ្ញាធរមួយចំនួន។ អាជ្ញាធរមួយចំនួនទៀត បានជម្លៀសបុគ្គលដែលត្រូវបានគេចោទនោះចេញពីតំបន់នោះ។ ប្រជាពលរដ្ឋក្នុងតំបន់ បានព្យាយាមដាក់ពាក្យបណ្តឹងផ្លូវការអំពីអំពើហិង្សានោះទៅមន្ត្រី គ.ជ.ប ឃុំ/សង្កាត់ ដែលទទួលបន្ទុកនៅក្នុងមណ្ឌលនោះ។ ផ្ទុយទៅវិញ មន្ត្រីនោះ បានដើរចូលទៅកាន់បន្ទប់ ដែលមន្ត្រីនោះប្រើប្រាស់ជាការិយាល័យរបស់ខ្លួន ហើយចាក់សោរពីខាងក្នុង។ មន្ត្រីនោះ ត្រូវបានគេឃើញថាបានដើរចុះឡើងនៅក្នុងបន្ទប់នោះ ហេតុដូចនេះហើយការអះអាងថាមន្ត្រីនោះ បានសន្លប់នៅក្នុងបន្ទប់ទៅកាន់សារព័ត៌មាន គឺមិនមែនជាការពិត។

បន្ទាប់មក កងរាជអាវុធហត្ថប្រហែល ២០នាក់ ក៏បានព្យាយាមបំបែកក្រុមប្រជាពលរដ្ឋ ដែលបានប្រមូលផ្តុំនៅមុខការិយាល័យរបស់មន្ត្រី គ.ជ.ប ឃុំ/សង្កាត់ នោះ។ ក្រុមប្រជាពលរដ្ឋ បានទាមទារឲ្យមន្ត្រី គ.ជ.ប ឃុំ/សង្កាត់ នោះដោះស្រាយបណ្តឹងរបស់អ្នកទាំងនោះ។ នៅខណៈនោះ ព្រឹត្តិការណ៍នៅរក្សាស្ថានភាពអហិង្សានៅឡើយ។ ក៏ប៉ុន្តែ ជាយថាហេតុ កងរាជអាវុធហត្ថចំនួនប្រហែល ១០០នាក់ បានធ្វើការរំកិលខ្លួនទៅរកក្រុមប្រជាពលរដ្ឋ។ ហេតុការណ៍នេះ បានធ្វើឲ្យមានអំពើហិង្សាមួយចំនួនកើតឡើង រួមមាន ការដុតរថយន្តរបស់កងរាជអាវុធហត្ថចំនួនពីរគ្រឿង។ កងរាជអាវុធហត្ថ ក៏បានបាញ់កាំភ្លើងចំនួនប្រហែល ១០គ្រាប់ ឡើងទៅលើ។ បុរសម្នាក់ ត្រូវបានវាយឲ្យរបួសដោយក្រុមបាតុករ ហើយបានបញ្ជូនទៅកាន់មន្ទីរពេទ្យ។

ព្រឹត្តិការណ៍ទាំងនេះ ត្រូវបានរាយការណ៍ដោយសារព័ត៌មានយ៉ាងច្រើន។

របាយការណ៍សង្ខេប លីកាដូ

## ឃុំសណ្ដាន់ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ

អ្នកសង្កេតការណ៍បានរាយការណ៍មកថា មានមនុស្សចំនួន ១០ នាក់ មិនអាចរកឈ្មោះឃើញក្នុងបញ្ជីនៅឯការិយាល័យលេខ ០៦១៩។

## ខេត្តព្រៃវែង

នៅសាលាបឋមសិក្សាក្ដីកណ្ដាល ភូមិ៥ ឃុំកំពង់លាវ ស្រុកព្រៃវែង អ្នកសង្កេតការណ៍បានរាយការណ៍មកថា មានប្រជាពលរដ្ឋប្រហែល ២០០នាក់ មិនអាចបោះឆ្នោតបាន ពីព្រោះគេបានប្រាប់ពួកគាត់ថា ពុំមានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ។

## មណ្ឌលបោះឆ្នោតវិទ្យាល័យព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត

នៅការិយាល័យលេខ ០៤៦៥ មានការប្រមូលផ្ដុំគ្នាយ៉ាងច្រើនកុះករ ហើយការមិនពេញចិត្តរបស់ប្រជាពលរដ្ឋកាន់តែខ្លាំងឡើងៗ ព្រោះឈ្មោះជាច្រើន ត្រូវបានលុបចេញពីបញ្ជីឈ្មោះបោះឆ្នោត។

## ស្រុកឧត្ដុង្គ ខេត្តកំពង់ស្ពឺ

អ្នកសង្កេតការណ៍ បានឃើញសកម្មជនគណបក្សកាន់អំណាច ចែកចាយអត្តសញ្ញាណប័ណ្ណនៅត្រឹមតែចម្ងាយប្រហែល ១០០ម៉ែត្រ ពីការិយាល័យបោះឆ្នោតលេខ ០៥៩៥ និង ០២៨៧។ ហើយនៅស្រុកឧត្ដុងនេះផងដែរ មានមនុស្ស ៧នាក់ បានបាត់ឈ្មោះពីបញ្ជីនៅការិយាល័យលេខ ០៦៣៣ និង ០៣១០។

## មណ្ឌលបោះឆ្នោតវត្តដំបូកខ្ពស់ រាជធានីភ្នំពេញ

នៅមណ្ឌលបោះឆ្នោតសាលារៀនវត្តដំបូងខ្ពស់ អ្នកសង្កេតការណ៍អង្គការ លីកាដូ បានទទួលពាក្យបណ្ដឹងមួយទៅលើមន្ត្រីមួយចំនួន ដែលបានប្រើប្រាស់ខ្មៅដៃដែលអាចលុបចេញបាន ជំនួសឲ្យការប្រើប្រាស់ប៊ិច សម្រាប់គូសឈ្មោះអ្នកដែលមកបោះឆ្នោតរួច នៅឯការិយាល័យបោះឆ្នោតលេខ ០៦២៩ ១៦៧២ និង ១០៩២។

## មណ្ឌលបោះឆ្នោតវិទ្យាល័យបាក់ទូក រាជធានីភ្នំពេញ

យោងតាមសំដីរបស់អ្នកសង្កេតការណ៍ជាច្រើនបានឲ្យដឹងថា ឈ្មោះជាច្រើនបានបាត់ពីបញ្ជីដោយនឹកស្មានមិនដល់។ ពលរដ្ឋដែលត្រូវគេដេញចេញបានខឹងសម្បារយ៉ាងខ្លាំង។ បុរសម្នាក់ដែលមិនត្រូវបានអនុញ្ញាតឲ្យបោះឆ្នោត បានស្ម័គ្រចិត្តកត់ឈ្មោះអ្នកដែលមិនអាចបោះឆ្នោតបានដទៃទៀត ហើយត្រូវបានគេគំរាមចាប់ខ្លួនដោយសារតែការធ្វើសកម្មភាពនោះ ទង្វើនេះបានធ្វើឲ្យមហាជនកាន់តែមិនសប្បាយចិត្តខ្លាំងឡើងៗ។

## ខេត្តព្រះសីហនុ

អ្នកសង្កេតការណ៍មួយចំនួន របស់អង្គការលីកាដូ ត្រូវបានគេប្រាប់ថាមានប្រជាពលរដ្ឋ ប្រហែល១០០នាក់ មិនអាចរកឈ្មោះឃើញនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតសាលាបឋមសិក្សាសាគូរ៉ា សង្កាត់លេខ១ ក្រុងព្រះសីហនុ។ ប្រជាពលរដ្ឋ បានកំពុងធ្វើការប្រមូលផ្ដុំតវ៉ានឹងការបាត់ឈ្មោះជាច្រើន។ បុរសម្នាក់បានរាយការណ៍ថា គាត់ត្រូវបានគេប្រាប់ឲ្យត្រឡប់ទៅវិញ ព្រោះគេបានសន្មត់ថាគាត់ បានបោះរួចហើយ។ ប្រជាពលរដ្ឋជាច្រើន បានអះអាងថាពួកគេតែងតែធ្វើការបោះឆ្នោតនៅការិយាល័យនេះ។ ហេតុដូចនេះ អ្នកទាំងនោះមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលដែលឈ្មោះរបស់អ្នកទាំងនោះ បានបាត់ចេញពីបញ្ជី។

នៅមណ្ឌលបោះឆ្នោតសាលាបឋមសិក្សាហ៊ុនសែន មិត្តភាព អ្នកសង្កេតការណ៍បានឃើញមានប្រជាពលរដ្ឋចំនួន ៥នាក់ ដែលមិនអាចបោះឆ្នោតបាន ព្រោះឈ្មោះរបស់អ្នកទាំងនោះមិនមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោតដោយមិននឹកស្មានដល់។ នៅក្នុង ការិយាល័យបោះឆ្នោតលេខ ០១៨៧ និង ០០៣៤ ក្នុងសង្កាត់៤ អ្នកសង្កេតការណ៍ បាននិយាយជាមួយបុរសម្នាក់ ដែលបានបង្ហាញពួកគេនូវប័ណ្ណព័ត៌មានបោះឆ្នោត ចំនួនពីរ នៅក្នុងការិយាល័យពីរផ្សេងគ្នា ដែលអាចធ្វើឲ្យបុរសម្នាក់នោះ អាចបោះ ឆ្នោតបានពីរដង។ នៅការិយាល័យលេខ ០០៣៦ ក្នុងសង្កាត់លេខ៤អ្នកសង្កេតការណ៍ បាននិយាយជាមួយស្ត្រីម្នាក់ដែលមិនអាចបោះឆ្នោតបាន ទោះបីជាស្ត្រីនោះមានគ្រប់ឯកសារត្រឹមត្រូវក៏ដោយ ព្រោះមានមនុស្សម្នាក់ត្រូវបានសន្មត់ថា បានបោះជំនួសនាងរួចទៅហើយ។



អ្នកបោះឆ្នោតមួយក្រុមនៅក្នុងការិយាល័យមួយនៅខេត្តព្រៃវែង មិនអាចបោះឆ្នោតបាន ដោយសារមិនមានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ។ ជាលទ្ធផល ក្រុមប្រជាពលរដ្ឋដែលរំជើបរំជួល មានចំនួនកាន់តែច្រើនឡើងៗ។



អ្នកបោះឆ្នោតមួយក្រុម ដែលត្រូវបានសង្ស័យថាជាអ្នកមកពីតំបន់ផ្សេង បានមកដល់ ដោយជិះរថយន្តទំនើបៗ។ ប្រជាពលរដ្ឋក្នុងឃុំបានប្រមូលផ្តុំគ្នាដើម្បីរាំងអ្នកទាំងនោះមិនឲ្យបោះឆ្នោត។

នៅក្នុងស្ថានការណ៍ជាច្រើន អ្នកសង្កេតការណ៍លីកាដូ បានសង្កេតឃើញថា មានពលរដ្ឋមួយក្រុមធំ បានមកដល់ភ្លាមៗ ដើម្បីបោះឆ្នោតនៅក្នុងឃុំ ជាកន្លែងដែលអ្នកទាំងនេះបានទទួលស្គាល់ថាខ្លួនពុំមានសិទ្ធិបោះឆ្នោតឡើយ។ អ្នកទាំងនោះបានធ្វើដំណើរមកដល់តាមក្បួនរថយន្តទំនើបៗ។ តាមពិតគឺ ប្រជាពលរដ្ឋទាំងនោះសុទ្ធតែមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ហើយមួយចំនួនធំ គឺនៅតាមមណ្ឌលដែលទើបតែបង្កើតឡើងថ្មីៗ ទោះបីជាពលរដ្ឋទាំងនោះ បានទទួលស្គាល់ថា ពួកគេពុំមែនជាអ្នកភូមិដែលរស់នៅក្នុងឃុំនោះក៏ដោយ។ ដែលរឿងនេះ បានបណ្តាលឲ្យមានការសង្ស័យចោទប្រកាន់ថា មានចេតនាក្នុងការចុះឈ្មោះបន្លំ។ បញ្ហានេះ ត្រូវតែមានការស៊ើបអង្កេតដោយឯករាជ្យ និងស្មោះត្រង់ច្បាស់លាស់។

## មណ្ឌលបោះឆ្នោតសាលាបឋមសិក្សាដំរីឆ្លង ឃុំស្អាង ខេត្តកណ្តាល

នៅមណ្ឌលសាលាបឋមសិក្សាដំរីឆ្លង ខេត្តកណ្តាល នៅពេលអ្នកសង្កេតការណ៍អង្គការលីកាដូ បានទៅដល់ទីនោះ ក៏បានឃើញមានមនុស្សយ៉ាងច្រើនកុះករ ឈរបិទទ្វារការិយាល័យបោះឆ្នោតលេខ ១២០៤។ ក្រោយពីធ្វើការសាកសួរជុំវិញបញ្ហានោះ អ្នកសង្កេតការណ៍អង្គការលីកាដូបានដឹងថាអ្នកភូមិជាច្រើនទាំងនោះបានបិទបន្ទប់នោះ ដោយដឹងថា មានមនុស្សមួយក្រុមធំ ដែលបានមកតម្រង់ជួរយ៉ាងវែងចូលបោះឆ្នោតក្នុងការិយាល័យលេខ ១២០៤ នោះ ជាក្រុមដែលត្រូវបានគេដឹកជញ្ជូនមកបោះឆ្នោតនៅទីនោះដោយមិនត្រឹមត្រូវ។

ក្រុមមនុស្សទាំងនោះ ដែលត្រូវបានរារាំងមិនឲ្យចូលទៅបោះឆ្នោតនោះ បានបញ្ជាក់ថា ពួកគេពុំដែលធ្លាប់បោះឆ្នោតនៅខេត្តកណ្តាលកាលពីមុនមកទេ។ ផ្ទុយទៅវិញ អ្នកទាំងនោះត្រូវបានគេនាំមកពីគ្រប់តំបន់នៃប្រទេសកម្ពុជា (អ្នកសង្កេតការណ៍អង្គការ លីកាដូបានសាកសួរបុគ្គលមួយចំនួន ដែលថាខ្លួនមកពីខេត្តសៀមរាប ស្វាយរៀង កំពង់ស្ពឺ និង ភ្នំពេញ)។ ប៉ុន្តែអ្នកទាំងនោះសុទ្ធតែមានឈ្មោះបោះឆ្នោត នៅខេត្តកណ្តាលទៅវិញ។

អ្នកសង្កេតការណ៍អង្គការ លីកាដូ ក៏បានសម្ភាសន៍ជាមួយសមាជិកមួយចំនួននៃក្រុមមួយក្នុងចំណោមក្រុមជាច្រើន ដែលត្រូវបានរារាំងក្នុងការបោះឆ្នោត។ អ្នកទាំងនោះបាននិយាយថា ក្រុមទាំងនោះមានគ្នាយ៉ាងតិច១០០នាក់ សុទ្ធតែជាកម្មករមកពីការដ្ឋានកិនថ្មមួយកន្លែង នៅខេត្តកំពង់ស្ពឺ ដែលត្រូវបានគេអះអាងថាជារបស់មន្ត្រីគណបក្សកាន់អំណាច នៅឃុំស្អាងភ្នំ ស្រុកស្អាងនោះ។

យោងតាមបុគ្គលម្នាក់នៅក្នុងក្រុមនោះ បានឲ្យដឹងថាថៅកែរបស់ពួកគេបានដឹកជញ្ជូនអ្នកទាំងនោះមកឃុំស្អាងភ្នំនេះ ជាលើកទីមួយ ដើម្បីបោះឆ្នោត។ ឆ្នាំមុន ក្នុងការបោះឆ្នោតឃុំ-សង្កាត់ ក្រុមមនុស្សទាំងនោះ បានអះអាងថា ពួកគេបានធ្វើដំណើរទៅផ្ទះតាមខេត្តរបស់អ្នកទាំងនោះរៀងៗខ្លួន ដើម្បីបោះឆ្នោត។ ក៏ប៉ុន្តែ នៅឆ្នាំនេះ អ្នកទាំងនោះត្រូវបានគេប្រាប់ថា ការដ្ឋានពុំមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុញ្ញាតឲ្យកម្មករទាំងអស់ ធ្វើដំណើរទៅតាមខេត្តរៀងៗខ្លួនដើម្បីបោះឆ្នោតនោះទេ។ ហេតុដូច្នេះ អ្នកទាំងនោះ ត្រូវបានគេប្រាប់ឲ្យទៅបោះឆ្នោតនៅខេត្តកណ្តាលវិញ ។

អ្នកសង្កេតការណ៍អង្គការ លីកាដូ បានជួបជាមួយប្រជាជនម្នាក់ដែលជាអ្នកបោះឆ្នោតម្នាក់ នៅក្នុងចំណោមអ្នកបោះឆ្នោតទាំងឡាយក្នុងការិយាល័យបោះឆ្នោតលេខ ១២០៤ ហើយបានបោះឆ្នោតក្នុងការិយាល័យនោះ មុនពេលដែលការិយាល័យនោះត្រូវបានរារាំងមិនឲ្យអ្នកដទៃបោះឆ្នោត។ ពេលសួរ គាត់ក៏បានសារភាពតាមត្រង់ថាគាត់មិនមែនជាប្រជាពលរដ្ឋរស់នៅក្នុងឃុំនេះទេ ប៉ុន្តែបាននិយាយថាឈ្មោះគាត់មាននៅក្នុងបញ្ជីបោះឆ្នោតនៅទីនេះ។ បន្ទាប់ពីបានធ្វើការសាកសួររួចហើយ មន្ត្រីស្រុកមួយចំនួនក៏បានមកដល់ ហើយព្យាយាមជជែកជំទាស់ជាមួយបុគ្គលិក លីកាដូ ដោយនិយាយថា ពលរដ្ឋកម្ពុជាមានសិទ្ធិបោះឆ្នោតទីណាក៏បានបានដែរ នៅទូទាំងប្រទេស។ ពេលដែលសួរត្រឡប់ទៅវិញ ស្រាប់តែមានមន្ត្រីស្រុកម្នាក់ បាននិយាយថា

ទោះជាប្រជាពលរដ្ឋទាំងនេះសុទ្ធតែពុំមានអាស័យដ្ឋានក្នុងឃុំនេះក៏ដោយ ប៉ុន្តែអ្នកទាំងនោះបានកសាងស្ពានជាច្រើននៅទីនេះ។

អ្នកភូមិក៏បានប្រាប់ថា ពលរដ្ឋដែលពុំមានសិទ្ធិបោះឆ្នោតទាំងនោះ ត្រូវបានដឹកមកជាក្រុមតាមរថយន្តទំនើបៗ ដែលមានស្លាកលេខ ភ្នំពេញ និង សៀមរាប។

អំឡុងពេលដែលមានការរំជើបរំជួលខ្លាំង ដោយក្រុមអ្នកភូមិ បានចាប់ផ្តើមដឹងថាមានក្រុមមនុស្សខាងក្រៅកំពុងចូលមកបោះឆ្នោតនោះ បុរសម្នាក់ត្រូវបានចាប់ខ្លួន។ គាត់ត្រូវបានឃុំឃាំងរហូតដល់យប់ ហើយពុំបានប្រាប់ថា ត្រូវចោទប្រកាន់ពីបទល្មើសអ្វីឡើយ។

បន្ទាប់ពីមានការបិទទ្វារដោយក្រុមប្រជាពលរដ្ឋអស់រយៈពេលពីរបីម៉ោង ការប្រមូលផ្តុំរបស់ប្រជាពលរដ្ឋកាន់តែបន្តកើនច្រើនឡើង ពេលនោះក៏មានកម្លាំងនគរបាលអន្តរាគមន៍ប្រហែល ១៥នាក់ ប្រដាប់ដោយខែលការពារ និងដំបងឆក់ បានមកដល់។ បន្ទាប់មក មន្ត្រីឃុំម្នាក់បាននិយាយយ៉ាងយូរដោយប្រើ ឧឃោសនស័ព្ទ (មេក្រូ) ដើម្បីព្យាយាមឲ្យក្រុម ប្រជាពលរដ្ឋចាកចេញពីការិយាល័យបោះឆ្នោត ប៉ុន្តែពុំបានសម្រេចលទ្ធផលទេ។ មន្ត្រីក៏បាន និយាយផងដែរថា ប្រសិនបើក្រុមមហាជនចាកចេញ ហើយអនុញ្ញាតឲ្យអ្នកមកពីឆ្ងាយបោះឆ្នោត នោះបុរសម្នាក់ដែលត្រូវបានចាប់ខ្លួននោះ នឹងត្រូវដោះលែងភ្លាម។ ចំនួនក្រុមមហាជន បានកើនឡើងរាប់រយនាក់ឈរពាសពេញចំពីមុខទ្វារ។ ដើម្បីបន្តរការតវ៉ា តទៅទៀត ក្រុមមហាជនបានធ្វើការប្រមូលថវិកាក្នុងចំណោមមហាជននានា ដើម្បីទិញអាហារ និង ទឹក ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋទាំងនោះឲ្យបន្តឈរបិទទ្វារតទៅទៀត។



នគរបាលបង្ក្រាបបាតុកម្ម បានព្យាយាមក្នុងការបំបែកក្រុមប្រជាពលរដ្ឋ ដែលកំពុងឈរបិទការិយាល័យបោះឆ្នោតលេខ ១២០៤ នៅស្រុកស្អាង ខេត្តកណ្តាល ប៉ុន្តែមិនបានសម្រេច។

ការិយាល័យបោះឆ្នោតលេខ ១២០៤ គឺជាការិយាល័យទើបនឹងបង្កើតថ្មីនៅក្នុង ឆ្នាំ២០១២ ដែលការបង្កើតនេះធ្វើឲ្យប្រជាពលរដ្ឋក្នុងឃុំមានការសង្ស័យជាខ្លាំង។ ការវិភាគទៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតសម្រាប់ការិយាល័យថ្មីនេះ បានបង្ហាញថាអត្រានៃឈ្មោះស្ទួនមានកម្រិតខ្ពស់យ៉ាងចម្លែក៖ ជាង ៣០ ភាគរយ នៃឈ្មោះមួយចំនួន ត្រូវបានចុះក្នុងបញ្ជីនៅក្នុងតំបន់ផ្សេងនៅក្នុងប្រទេសកម្ពុជា។ អត្រានៃឈ្មោះស្ទួននៅទូទាំងប្រទេស គឺមានតិចជាង ២ ភាគរយប៉ុណ្ណោះ។ ករណីនេះ មានភាពស្របទៅនឹងការអះអាងរបស់ក្រុមមនុស្សខាងក្រៅ ដែលត្រូវបានរារាំងដោយក្រុម ប្រជាពលរដ្ឋក្នុងឃុំ និងចោទថា មិនមានទីលំនៅនៅក្នុងឃុំនេះ។

បន្ទាប់ពីទៅសង្កេតការណ៍នៅការិយាល័យបោះឆ្នោតនោះ បុគ្គលិកអង្គការ លីកាដូ និងបុគ្គលិកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានព្យាយាមចូលទៅជួបបុរសម្នាក់ដែលត្រូវបានគេឃុំខ្លួន ប៉ុន្តែត្រូវបានបដិសេធក្នុងការជួបដោយនគរបាលស្រុក។

ព្រឹត្តិការណ៍នេះ បានបង្ហាញយ៉ាងច្បាស់នូវឧទាហរណ៍នៃការបន្លំដោយមានចេតនា និងរៀបចំទុកជាមុន ដែលប្រព្រឹត្តដោយមន្ត្រីមួយចំនួនដែលទទួលបន្ទុកគ្រប់គ្រងបញ្ជីឈ្មោះបោះឆ្នោត។ នេះ ក៏បានផ្តល់នូវឧទាហរណ៍យ៉ាងរឹងមាំមួយស្តីពីបុគ្គលមួយចំនួន ដែលធ្លាប់បានបោះឆ្នោតនៅពេលបោះឆ្នោតលើកមុន ហើយត្រូវបានរារាំងមិនឲ្យបោះនៅក្នុងពេលបោះឆ្នោតលើក

## សាលារៀនពាមសាលា ឃុំស្អាងភ្នំ ខេត្តកណ្ដាល

នៅពេលដែលអ្នកសង្កេតការណ៍អង្គការ លីកាដូ បានមកដល់សាលារៀនពាមសាលាភ្លាម អ្នកទាំងនោះ បានសង្កេតឃើញថាមានក្រុមយុវជន និងមនុស្សចាស់ជនជាតិខ្មែរ ចម្លែកមួយក្រុម កំពុងអង្គុយនៅមុខផ្ទះឯកជនមួយ នៅទល់មុខសាលារៀន។ នៅពេលដែលចូលដល់ក្នុងបរិវេណសាលារៀន អ្នកស្រុកបានមករកក្រុមអ្នកសង្កេតការណ៍ភ្លាមៗ ដើម្បីពន្យល់អំពីមនុស្សចម្លែក កំពុងបោះឆ្នោតនៅក្នុងការិយាល័យលេខ ០៩៦៩។ នៅពេលដែលអ្នកទាំងនោះកំពុងនិយាយ ក្រុមយុវជន និងមនុស្សចាស់ចម្លែកនោះ បានដើរឆ្លងផ្លូវ ហើយព្យាយាម (ត្រូវបានគេរាយការណ៍ថាបានព្យាយាមចូលក្នុងការិយាល័យចំនួន ៣ដង មកហើយ) ចូលក្នុងសាលារៀនដើម្បីបោះឆ្នោត។ អ្នកទាំងនោះ ត្រូវបានរារាំងដោយក្រុមប្រជាពលរដ្ឋក្នុងឃុំមួយក្រុម មិនឲ្យចូលក្នុងការិយាល័យបោះឆ្នោត។

បុគ្គលិករបស់អង្គការ លីកាដូ បានធ្វើការសាកសួរបុរសម្នាក់ក្នុងចំនោមបុរសចម្លែកទាំងនោះ ដែលកំពុងព្យាយាមចូលក្នុងសាលារៀនដើម្បីបោះឆ្នោត ថាតើបុរសនោះមានសិទ្ធិបោះឆ្នោត ឬទេ។ បុរសនោះបានឆ្លើយតបថា៖ "មាន ព្រោះខ្ញុំមានឈ្មោះនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត"។ បន្ទាប់មក បុគ្គលិកអង្គការ លីកាដូ ក៏បានសួរទៀតថា តើបុរសនោះ អាចបង្ហាញពីឯកសារស្របច្បាប់នានាសម្រាប់បោះឆ្នោតបានឬទេ។ បុរសនោះ បានបង្ហាញទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត (ICE) ដែលមានរូបថត និងឈ្មោះរបស់គាត់ចំនួនពីរផ្សេងគ្នា។ ទម្រង់ទាំងពីរនេះ គឺសម្រាប់ការិយាល័យបោះឆ្នោតពីរផ្សេងគ្នា ដែលមួយក្នុងចំណោមទម្រង់ទាំងពីរ គឺសម្រាប់ការិយាល័យបោះឆ្នោតក្នុងមណ្ឌលពាមសាលា។
នៅពេលដែលអ្នកសង្កេតការណ៍ បានសួរបុរសនោះអំពី ថាតើគាត់ទទួលបានសិទ្ធិបោះឆ្នោតពីរដងដោយរបៀបណា បុរសនោះ ក៏បានដកទម្រង់លិខិតបញ្ជាក់អត្ត-សញ្ញាណសម្រាប់ការបោះឆ្នោតមួយចេញពីដៃរបស់អ្នកសង្កេតការណ៍ រួចនិយាយថា លិខិតនោះជាលិខិតសរសេរខុសទេ។

ហេតុការណ៍ដូចគ្នាដែរ ត្រូវបានសង្កេត-ការណ៍ភ្លាមៗ នៅឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល។ បុរសម្នាក់ ដែលកាន់នូវលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត (ICE) បានបង្ហាញដល់អ្នកសង្កេតការណ៍អង្គការ លីកាដូ បុរសនោះមានលិខិតនោះពីរសន្លឹកផ្សេងគ្នា និងមានបិទរូបថត និងឈ្មោះរបស់បុរសនោះ នៅលើលិខិតទាំងពីរនោះ សម្រាប់ការិយាល័យ បោះឆ្នោតពីរផ្សេងគ្នា។

នេះ ទោះបីជាអ្នកទាំងនោះចង់បោះក៏ដោយ ដោយសារអ្នកទាំងនោះត្រូវបានគេរាំងក្នុងការធ្វើដំណើរទៅកាន់មណ្ឌលបោះឆ្នោត ដែលអ្នកទាំងនោះបានចុះឈ្មោះដោយស្របច្បាប់។ ជាថ្មីម្តងទៀត ភាគរយខ្ពស់នៃឈ្មោះអ្នកបោះឆ្នោតស្ទួននៅក្នុងឃុំនេះ ក៏ជាអំណះអំណាងបន្ថែមដល់ការសង្កេតការណ៍ទាំងនេះផងដែរ។



ការិយាល័យនគរបាលស្រុកស្អាង ដែលជាកន្លែងអ្នកភូមិម្នាក់ត្រូវបានឃាត់ខ្លួន គ្រប់អគារទាំងអស់សុទ្ធតែមានសរសេរអក្សរ "អំណោយសម្តេចហ៊ុនសែន និងលោកជំទាវ"។

## ក្បួនរថយន្តទំនើបៗ បានដឹកជញ្ជូនមនុស្សមួយក្រុមធំ ដើម្បីមកបោះឆ្នោតនៅស្រុកកៀនស្វាយ ខេត្តកណ្តាល

នៅឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល មនុស្សជាច្រើនពីក្នុងចំនោមប្រជាពលរដ្ឋជាច្រើនដែលបានប្រមូលផ្តុំគ្នា បានរាយការណ៍ថា កាលពីព្រឹកព្រលឹមនៅក្នុងថ្ងៃបោះឆ្នោតនោះ មានរថយន្តទំនើបៗប្រហែលជា ១០ គ្រឿង ជិះដោយមនុស្សមួយក្រុម ដែលមានសំលៀកបំពាក់ស្អាតបាត មានគ្នាប្រហែល ៨០នាក់ បានមកដល់ដើម្បីបោះឆ្នោតនៅទីនោះ។ ប្រជាពលរដ្ឋនៅទីនោះ មិនមានអ្នកណាស្គាល់មនុស្សមួយក្រុមនោះទេ។ ប៉ុន្តែប្រជាពលរដ្ឋបានធ្វើការតវ៉ា នៅពេលដែលមនុស្សទាំងនោះបានបោះឆ្នោត។ ដោយមានសំពាធពីប្រជាពលរដ្ឋអំពីប្រវត្តិរបស់អ្នកទាំងនោះ មនុស្សមួយចំនួននៃក្រុមនោះ បាននិយាយថាពួកគេមកពីគណកម្មាធិការគណបក្សកាន់អំណាចចុះពង្រឹងមូលដ្ឋាន។ បុគ្គលពីរនាក់ នៃក្រុមនោះ បានបង្ហាញនាមប័ណ្ណរបស់អ្នកទាំងពីរ ដោយម្នាក់ឈ្មោះ ងួ សុវណ្ណ ជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងម្នាក់ទៀតឈ្មោះ ហេង សុខា ជាអនុរដ្ឋលេខាធិការនៃរាជរដ្ឋាភិបាល។ ការផ្ទៀងផ្ទាត់បញ្ជីឈ្មោះបោះឆ្នោតបានបង្ហាញថាលោកងួសុវណ្ណបានចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យពីរផ្សេងទៀតផងដែរ។ អ្នកសង្កេតការណ៍ ត្រូវបានគេគំរាមកំហែងចាប់ខ្លួន នៅពេលព្យាយាមបញ្ឈប់ក្រុមមនុស្សនោះដោយផ្ទាល់មាត់ ពីការបោះឆ្នោត។

## អ្នកបោះឆ្នោតមួយក្រុមបានត្រលប់ទៅវិញ ដោយមិនបានបោះឆ្នោត ដោយសារប្រជាពលរដ្ឋ ក្នុងសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល បានធ្វើការរារាំង

នៅមុនការបិទការិយាល័យបោះឆ្នោតបន្តិច នៅម៉ោង ៣ ល្ងាច អ្នកសង្កេតការណ៍អង្គការលីកាដូ បានធ្វើដំណើរទៅកាន់មណ្ឌលបោះឆ្នោតសាលារៀន ព្រែកសំរោង ក្នុងខេត្តកណ្តាល។ នៅមុនពេលបុគ្គលិកអង្គការ លីកាដូ បានទៅដល់បន្តិច កងរាជអាវុធហត្ថដែលប្រដាប់ដោយអាវុធ និងមន្ត្រីនគរបាល ត្រូវបានបញ្ជូនទៅទីនោះ ដើម្បីគំរាមកំហែងប្រជាពលរដ្ឋមួយក្រុម ដែលកំពុងធ្វើការប្រមូលផ្តុំគ្នានៅក្នុងសាលារៀន។

នៅពេលដែលអ្នកសង្កេតការណ៍អង្គការ លីកាដូ បានទៅដល់ ស្ត្រីម្នាក់ដែលពូកែនិយាយបានធ្វើការរំលឹកនូវសកម្មភាព ដែលមន្ត្រីឃុំអនុញ្ញាតឲ្យអ្នកបោះឆ្នោតមួយក្រុមធំ ចូលទៅបោះឆ្នោតក្នុងការិយាល័យលេខ ១២៦១។ ប្រជាពលរដ្ឋក្នុងឃុំ បាននិយាយថា អ្នកបោះឆ្នោតមួយក្រុមនោះ គឺជាមនុស្សមកពីខាងក្រៅ ហើយមនុស្សមួយចំនួនក្នុងក្រុមនោះ បានបោះឆ្នោត ដោយប្រើលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត (ប័ណ្ណខៀវ)។ ស្ត្រីម្នាក់ ដែលត្រូវបានគេរាយការណ៍ថា បានបោះឆ្នោតដោយប្រើទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត

## ឃុំរីករាយ ស្រុករវាង ខេត្តព្រះវិហារ

អង្គការលីកាដូ បានទទួលរបាយការណ៍ថា សមាជិកគណបក្សប្រជាជន បាននាំអ្នកភូមិ ទៅបោះឆ្នោត នៅមណ្ឌលលេខ ០០៦៦ និង ០០៦៧ ហើយក្រោយមកស្នាក់នៅជិតៗ កន្លែងរាប់ សន្លឹកឆ្នោតនោះ។ ការិយាល័យនោះ មានការចុះឈ្មោះកើនឡើងរហូតដល់ ៩៦ ភាគរយ ដែលគួរឲ្យភ្ញាក់ផ្អើលយ៉ាងខ្លាំង។

ដែលក្នុងលិខិតនោះសរសេរថាជាភេទប្រុស។ ប្រជាពលរដ្ឋក្នុងឃុំ បានព្យាយាមរារាំងស្ត្រីនោះពីការបោះឆ្នោត ប៉ុន្តែមេឃុំ បាននិយាយថា គាត់ធានាចំពោះស្ត្រីនោះ និងរុញស្ត្រីនោះចូលក្នុងការិយាល័យបោះឆ្នោត។

អ្នកសង្កេតការណ៍អង្គការ លីកាដូ មិនបានឃើញហេតុការណ៍នោះពីដំបូងឡើយ ប៉ុន្តែអ្នកឃ្លាំមើលមួយចំនួន បានឃើញកងរាជអាវុធហត្ថ និងនគរបាលជាច្រើន បានឈរនៅខាងក្រោយច្រកចេញចូលសាលារៀន ហើយបានបញ្ជាក់អំពីព្រឹត្តិការណ៍នោះជាមួយអ្នកសង្កេតការណ៍ដទៃទៀត។



អ្នកភូមិមួយចំនួននៅការិយាល័យបោះឆ្នោតជាច្រើន ត្រូវបានគេសង្កេតឃើញថាបានធ្វើការរៃអង្គាសប្រាក់កាសសម្រាប់ទិញអាហារ ដើម្បីឲ្យក្រុមប្រជាពលរដ្ឋបន្តស្ថិតនៅក្នុងមណ្ឌលបោះឆ្នោតពេញមួយថ្ងៃ ដើម្បីឃ្លាំមើលភាពមិនប្រក្រតីនានា។

## កងកម្លាំងប្រដាប់អាវុធជាច្រើននាក់ បានធ្វើដំណើរជាច្រើនក្រុមធំៗ ដើម្បីទៅបោះឆ្នោតនៅភាគខាងជើង ខេត្តសៀមរាប

នៅមណ្ឌលបោះឆ្នោតសាលារៀន ត្រពាំងក្រសាំង ដែលមានការិយាល័យបោះឆ្នោតលេខ ១១៤៣ ១១០៣ ១១៧៣ និង ០៨១៥ នៅក្នុងភូមិគោកត្នោត ឃុំគោកចក ស្រុកវ៉ារិន្ទ មានក្រុមទាហាន ប្រហែល ១,២០០នាក់ មកពីកងពិសេសលេខ ៩១១ (មកពីតំបន់បុស្សរូ នៅភាគខាងកើតនៃខេត្តព្រះវិហារ និងមកពីឃុំត្រពាំងត្រាវ ស្រុកលន្លង់វ៉ែង ខេត្តឧត្តរមានជ័យ) ត្រូវបានដឹកមកបោះឆ្នោតនៅទីនោះ។ភូមិត្រពាំងក្រសាំង គឺជាភូមិថ្មី ដែលមានមណ្ឌលបោះឆ្នោតចំនួនពីរ។

ក៏ដូចគ្នាដែរ នៅស្រុកវ៉ារិន្ទ អ្នកសង្កេតការណ៍អង្គការ លីកាដូ នៅឯការិយាល័យបោះឆ្នោតលេខ ១១៤២ និង ០៨៧៧ នៅក្នុងសាលាបឋមសិក្សារូមរន់ថ្មី បានឃើញទាហានចំនួន ៦០០នាក់ ដែលមកពីកងពិសេសលេខ ៩១១ ដូចគ្នា មកបោះឆ្នោតនៅក្នុងមណ្ឌលនេះដែរ។ ទាហានទាំងនោះ ត្រូវបានដឹកជញ្ជូនមកដោយរថយន្តយោធាចំនួន ៨ គ្រឿង ពាក់ស្លាកលេខកងយុទ្ធពលខេមរភូមិន្ទ។ អ្នកសង្កេតការណ៍ បានរាយការណ៍ថា ក្រៅពីទាហានទាំងនោះ គឺមានតែពី ២០ ទៅ៤០ នាក់ប៉ុណ្ណោះជាប្រជាពលរដ្ឋស៊ីវិល។ ទាហានទាំងនោះ សម្រាកនៅក្នុងវត្ត ១កន្លែងផងដែរ។ការិយាល័យលេខ១១៤២ក៏ជាការិយាល័យថ្មីមួយដែរដែលទើបបង្កើតឡើងក្នុងឆ្នាំនេះ។ នេះ កាន់តែឲ្យមានការសង្ស័យថែមទៀត ដោយនៅក្នុងការិយាល័យនោះ បានបង្ហាញឲ្យឃើញថាមានចំនួនស្ត្រីតិចយ៉ាងចម្លែក ធៀបទៅនឹងចំនួនបុរសនៅក្នុងបញ្ជី។

នៅក្នុងមណ្ឌលបោះឆ្នោតសាលាបឋមសិក្សា ចាន់គិរី ភូមិគោកកណ្តាល ឃុំល្វាក្រាំង ស្រុកវ៉ារិន្ទ ខេត្តសៀមរាប មានការិយាល័យបោះឆ្នោតចំនួន ២។ ការិយាល័យបោះឆ្នោតលេខ ០៧៨១ ត្រូវបានបង្កើតឡើងសំរាប់ជនស៊ីវិល ហើយការិយាល័យលេខ ១១១៥ សំរាប់យោធា។ មានអ្នកបោះឆ្នោតសរុបចំនួន ៦៩២នាក់ នៅការិយាល័យលេខ ១១១៥ ដោយ ៦៥០នាក់ សុទ្ធតែជាបុរស ស្ត្រីតែពីរនាក់គត់។ នេះក៏ជាមណ្ឌលបោះឆ្នោតថ្មី មួយដែរ។

អ្នកសង្កេតការណ៍ក៏បានកត់សំគាល់ឃើញផងដែរថា មានអ្នកបោះឆ្នោតជាច្រើននាក់ប្រើ

## និស្សិតសាកលវិទ្យាល័យចេនឡាជាច្រើនរយនាក់ ត្រូវបានបញ្ជូនទៅបោះឆ្នោតនៅស្រុកល្វាឯម ខេត្តកណ្តាល

និស្សិតនៃសាកលវិទ្យាល័យចេនឡាជាច្រើនរយនាក់ ត្រូវបានគេចុះឈ្មោះដើម្បីបោះឆ្នោតដោយមិនត្រឹមត្រូវ នៅឯការិយាល័យទើបបង្កើតថ្មីមួយ លេខ ០៧៧៤ ក្នុងឃុំបឹងក្រោម ស្រុកល្វាឯម ខេត្តកណ្តាល។ ទោះបីជាឈ្មោះរបស់អ្នកទាំងនោះ មាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោតក៏ដោយ ក៏និស្សិតភាគច្រើនលើសលប់ មិនមានសិទ្ធិស្របច្បាប់ក្នុងការបោះឆ្នោតនៅក្នុងឃុំនោះទេ ព្រោះអ្នកទាំងនោះមិនមានទីលំនៅនៅទីនោះ។ បន្ទាប់ពីប្រជាពលរដ្ឋក្នុងឃុំ បានដឹងថាក្រុមនិស្សិតមួយក្រុមនេះ ដែលមកទីនេះដើម្បីបោះឆ្នោត (ដែលត្រូវបានគេសង្ស័យថាក្រោមការណែនាំពីសាស្ត្រាចារ្យរបស់អ្នកទាំងនោះ) គឺមិនមានសិទ្ធិបោះឆ្នោតនៅទីនោះនោះ ប្រជាពលរដ្ឋទាំងនោះបានធ្វើការប្រមូលផ្តុំគ្នារារាំងនិស្សិតដែលនៅសេសសល់មិនទាន់បោះឆ្នោត ពីការបោះឆ្នោត។ គួរកត់សម្គាល់ផងដែរ ថាបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំបឹងក្រោមនេះ បានបង្ហាញថា ចំនួនប្រជាពលរដ្ឋក្នុងឃុំ បានចុះឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត មានអត្រាលើសដល់ទៅ ១១៤,៦៦ភាគរយ។

នេះមិនមែនជាលើកទីមួយទេ ដែលសាកលវិទ្យាល័យចេនឡា មានការជាប់ទាក់ទងយ៉ាងច្បាស់ជាមួយគណបក្សនយោបាយ។ គេហទំព័ររបស់សាកលវិទ្យាល័យក្នុងបណ្តាញសង្គមហ្វេសប៊ុក កាលពីមុនបានបង្ហោះកម្រងរូបភាពនៃសិស្សនិស្សិត ធ្វើការតវ៉ាប្រឆាំងនឹងលោក កឹម សុខា ក្នុងពេលដែលអ្នកសង្កេតការណ៍ជឿជាក់ថា ជាយុទ្ធនាការពាក់ព័ន្ធនឹងរឿងនយោបាយ ទៅលើអនុប្រធានគណបក្សសង្គ្រោះជាតិ។ សាកលវិទ្យាធិការ/ម្ចាស់សាកលវិទ្យាល័យចេនឡា គឺជាអនុរដ្ឋ-លេខាធិការក្រសួងការបរទេស ឆ្នាំ២០០៧ ទោះបីជាតួនាទីបច្ចុប្បន្នរបស់បុគ្គលនោះមិនត្រូវបានដឹងច្បាស់ក៏ដោយ។

ប្រាស់ ទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសំរាប់បោះឆ្នោត (ប័ណ្ណខៀវ) នៅក្នុងឃុំចុងឃ្នាស។

ការបង្ហាញទាំងអស់ខាងលើនេះ ជាការបង្ហាញសង្ខេបៗ និងច្បាស់ៗ អំពីករណីបោះឆ្នោត បន្លំខុសច្បាប់ ដែលទាមទារឲ្យមានការស៊ើបអង្កេតយ៉ាងហ្មត់ចត់។ នៅមណ្ឌលណាដែលយោធាបោះឆ្នោតដោយមិនត្រឹមត្រូវ គួរតែធ្វើការផ្ទេរទៅឃុំដែលអ្នកទាំងនោះធ្លាប់បានបោះឆ្នោតស្របច្បាប់វិញ ប្រសិនបើអាចធ្វើបាន។ សន្លឹកឆ្នោតដែលត្រូវបានបោះដោយមិនត្រឹមត្រូវ គួរតែចាត់ទុកជាមោឃៈ។ នៅតាមមណ្ឌលណាដែលមានអ្នកភូមិ និងយោធាមិនមានសិទ្ធិបោះឆ្នោតរួមគ្នា គួរតែមានការត្រួតពិនិត្យ អំពីបញ្ជីបោះឆ្នោត និងត្រូវបោះឡើងវិញនៅការិយាល័យនោះ។

## ប្រជាពលរដ្ឋប្រមូលផ្តុំគ្នា ដើម្បីជំទាស់ជាមួយក្រុមអ្នកបោះឆ្នោតមួយក្រុមធំ ដែលមានសិទ្ធិបោះឆ្នោត

ពួកអ្នកភូមិបានប្រមូលផ្តុំគ្នា ដើម្បីជំទាស់ជាមួយក្រុមអ្នកបោះឆ្នោតមួយក្រុមធំ នៅឃុំ រាទ៉ រ ស្រុកព្រះស្តេច ខេត្តព្រៃវែង អ្នកសង្កេតការណ៍ ក៏បានត្រួតពិនិត្យជម្លោះធំមួយរវាង អ្នកសង្កេតការណ៍គណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ ហើយលទ្ធផលនៃការចោទប្រកាន់ គឺមានជនស៊ីវិលជាង ៤០០នាក់ ដែលមិនចេះនិយាយភាសាខ្មែរ ហើយអ្នកទាំងទំនងជាជនជាតិវៀតណាម ដែល ត្រូវបាននាំមកសម្រាប់តែបោះឆ្នោតក្នុងឃុំនោះប៉ុណ្ណោះ។ ការិយាល័យបោះឆ្នោត ២ កន្លែង ត្រូវបានបិទដោយបង្ខំ អស់រយៈពេល ២ ទៅ ៣ម៉ោង ហើយក្រោយមកក៏បើកឡើងវិញ។ អ្នកគាំទ្រគណៈបក្សសង្គ្រោះជាតិ បានព្យាយាមរារាំងក្រុម ដែលត្រូវបានគេអះអាងថា អ្នកមកពីក្រៅនោះ។

មេឃុំរាទ៉ រ បានរាយការណ៍ប្រាប់បុគ្គលិកអង្គការលីកាដូ ថាឃុំនេះ មិនត្រឹមតែមានអត្រាខ្ពស់នៃការចុះបញ្ជីឈ្មោះបោះឆ្នោតលើសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណជាច្រើនត្រូវបានចេញថែមទៀតផង។ ជាការពិត អង្គការលីកាដូ បានធ្វើការបញ្ជាក់ថា លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត (ICE) មានចំនួន ១៣៣១ សន្លឹក ត្រូវបានចេញ ក្នុងឃុំរាទ៉ រ។ តួរលេខនេះ បង្ហាញថាជាង ៣០ភាគរយ នៃប្រជាពលរដ្ឋបានចុះឈ្មោះក្នុងបញ្ជី ឈ្មោះបោះឆ្នោតក្នុងឃុំនេះ។ លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត (ICE) ជាមធ្យមទូទាំងប្រទេស គឺមានតិចជាង ១០ភាគរយ ប៉ុណ្ណោះ។ នេះមិនអាចទៅរួចទេ ដែល ៣០ភាគរយ នៃចំនួនប្រជាពលរដ្ឋក្នុងឃុំរាទ៉ រ បានបាត់ទម្រង់លិខិតមានរូបថតដែលអាចទទួលយកបានទាំងអស់ សម្រាប់ការបោះឆ្នោត ហើយហេតុដូចនេះហើយ ទើបត្រូវការលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត (ICE) ។

ឃុំនេះ គួរតែត្រូវធ្វើការស៊ើបអង្កេតទៅលើការដកសិទ្ធិក្នុងការបោះឆ្នោតដោយមិនត្រឹមត្រូវដោយផ្អែកលើពូជសាសន៍ ដែលជាបញ្ហានឹងត្រូវធ្វើការពិភាក្សាពេលក្រោយក្នុងរបាយការណ៍នេះ។

នៅឃុំ ក្តឿងរាយ ស្រុកកញ្ជៀច អ្នកសង្កេតការណ៍ក៏បានពិនិត្យឃើញការតវ៉ាជំទាស់ក្រុមមនុស្សដែលហៅថា ក្រុមមនុស្សដែលមិនអាចបោះឆ្នោត។ អាជ្ញាធរបានគំរាមកំហែងចាប់ខ្លួនអ្នកតវ៉ា ហើយជាយថាហេតុក៏បានឃុំខ្លួនបុរស ២នាក់។ ប៉ុន្តែម្នាក់ក្នុងចំណោមពីរនាក់នោះបានគេចខ្លួនពីរថយន្តរបស់នគរបាល។ អ្នកសង្កេតការណ៍លីកាដូ ក៏ត្រូវនគរបាលតាមដានជាប់ជាប្រចាំដែរ។ យោធា កងរាជអាវុធហត្ថ ព្រមទាំងនគរបាលស្លៀកពាក់ឯកសណ្ឋាន មានវត្តមាន



យោធា និងកងរាជអាវុធហត្ថ បានធ្វើសកម្មភាពនៅមណ្ឌលបោះឆ្នោត ក្នុងខេត្តព្រៃវែង។

នៅគ្រប់ការិយាល័យបោះឆ្នោត។ មុនពេលមានការតវ៉ា មន្ត្រី និង បុរសដែលមានបិទផ្លាកសញ្ញា គណបក្សប្រជាជននៅលើទូរស័ព្ទ បានចូលមកជិត អ្នកសង្កេតការណ៍ និងក្រុមប្រជាពលរដ្ឋស៊ីវិលក្នុង បំណងថតរូបជិត ដើម្បីបំភិតបំភ័យអ្នកទាំងនោះ។

នៅសាលារៀនអំពិលក្រៅឃុំអំពិលក្រៅកងកម្លាំងប្រដាប់អាវុធ បានចល័តទៅមក ដើម្បីរារាំងពលរដ្ឋ ពីការតវ៉ា ជំទាស់នឹងក្រុមមនុស្ស ដែលហៅថាមនុស្សចម្លែក មិនអាចបោះឆ្នោតនៅការិយាល័យ ០៩៨២ និង ០៩៨១។

## នៅវត្តព្រៃតូច ក្នុងឃុំព្រៃកគយ ស្រុកស្អាង ខេត្តកណ្តាល

ទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណយ៉ាងច្រើន ត្រូវបានប្រើប្រាស់នៅមណ្ឌលបោះឆ្នោតតូចមួយហៅថា មណ្ឌលវត្តព្រៃតូច ការិយាល័យលេខ ០៩២២ ក្នុងឃុំព្រៃកគយ ស្រុកស្អាង ខេត្តកណ្តាល។ សមាជិកក្រុមប្រឹក្សាឃុំព្រៃកគយ បានរាយការណ៍ប្រាប់អ្នកសង្កេតការណ៍ លីកាដូ ថា ឲ្យទៅសង្កេតមើលមណ្ឌលវត្តព្រៃតូចដ៏តូចមួយនេះផង ព្រោះមានការប្រើប្រាស់ទម្រង់បញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត (ICE) យ៉ាងច្រើន។

ពេលទៅដល់ បុគ្គលិកលីកាដូ បានឃើញ មនុស្ស៤នាក់ ឈរក្នុងជួរដែលមានគ្នា ១០នាក់ កាន់ទម្រង់បែបនេះចូលទៅបោះឆ្នោត។ អាជ្ញាធរដែនដី មានការភិតភ័យដោយឃើញមានវត្តមានអ្នកសង្កេត-ការណ៍ នៅក្នុងបរិវេណវត្ត ហើយភ្លាមនោះក៏បាននិយាយគ្នាតាមវិទ្យុទាក់ទង។ អ្នកភូមិបានខ្សិបប្រាប់អ្នកសង្កេតការណ៍លីកាដូ ថាឲ្យនៅក្នុងវត្តនេះសិនហើយ ដើម្បីចៀសវាងកុំឲ្យមានអ្នកចម្លែកចូលមកបោះឆ្នោត ដោយប្រើប្រាស់ទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណបែបនេះ។ ប៉ុន្តែ អ្នកសង្កេតការណ៍លីកាដូ បានចាកចេញ ទៅសង្កេតការណ៍នៅការិយាល័យផ្សេងទៀត (ក្រុមចល័ត)។



អ្នកឃ្លាំមើលការបោះឆ្នោត ត្រូវបានគេថតរូបជិត នៅខេត្តព្រៃវែង។

ពេលពិនិត្យមើលឈ្មោះអ្នកបោះឆ្នោតនៅមណ្ឌលនេះ ឃើញថា មានចំនួនឈ្មោះជនជាតិវៀតណាម យ៉ាងច្រើន។ ប៉ុន្តែតំបន់នេះជាតំបន់ដែលមានជនជាតិវៀតណាមរស់នៅច្រើន។ ហើយដូច្នេះ នេះជាការសំខាន់ក្នុងការកត់សម្គាល់ថា បើមិនមានការធ្វើទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណបោះឆ្នោតត្រឹមត្រូវទេ យើងស្ទើរតែមិនអាចបែងចែកឲ្យដាច់បានរវាងជនជាតិខ្មែរ ដែលមានដើមកំណើតវៀតណាម និងប្រជាពលរដ្ឋដែលមិនមែនជនជាតិខ្មែរ។

ឃុំព្រៃកគយ ក្នុងពេលចុះឈ្មោះបោះឆ្នោត គឺជាតំបន់មួយដែលមានបញ្ហាច្រើន ក្នុងចំណោមតំបន់នានាក្នុងខេត្តកណ្តាល ដោយមានអត្រាចុះឈ្មោះ រហូតដល់ ១៣៩.៦៣ភាគរយ។ ការចុះទៅស៊ើបអង្កេតដោយអ្នកឃ្លាំមើលសិទ្ធិមនុស្ស លីកាដូ មុនបោះឆ្នោត១ថ្ងៃ បញ្ជាក់ឲ្យឃើញថា បញ្ហាការចុះឈ្មោះច្រើនហួសប្រមាណនេះ សមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្ស សម រង្ស៊ី និង សិទ្ធិមនុស្ស មានការព្រួយបារម្ភយ៉ាងខ្លាំងអំពីបញ្ហាកើនចំនួនអ្នកបោះឆ្នោតនេះធៀបទៅនឹងចំនួនអ្នកភូមិ ដែលរស់នៅ នៅក្នុងឃុំនេះ។



យុវជនទាំងនេះ ត្រូវបានអ្នកភូមិក្នុងឃុំស្គាល់ថាជាអ្នកមកពីតំបន់ផ្សេង។ បុរសម្នាក់ដែលឈរនៅខាងស្តាំឆ្ងាយជាងគេ កំពុងកាន់ទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត (ប័ណ្ណខៀវ) ចំនួនពីរ ដែលអនុញ្ញាតឲ្យគាត់បោះឆ្នោតបានពីរការិយាល័យផ្សេងគ្នា។

អ្នកសង្កេតការណ៍អង្គការ លីកាដូ នៅទូទាំងប្រទេស បានជួបប្រទះនូវបញ្ហាដែលអ្នកបោះឆ្នោត និងអ្នកបោះឆ្នោតសំខាន់មួយចំនួន ត្រូវបានគំរាមកំហែងដោយអាជ្ញាធរមួយចំនួន (ហើយក្នុងករណីមួយចំនួនដោយប្រជាពលរដ្ឋផ្សេងទៀត) តាមគ្រប់រូបភាព។ ឧទាហរណ៍៖

## ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល

ព្រឹត្តិការណ៍មួយ ក្នុងការិយាល័យបោះឆ្នោតក្នុងវត្តកេត្តឧត្តម ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល អ្នកសង្កេតការណ៍ លីកាដូ បានកត់សម្គាល់ឃើញថា ប្រជាពលរដ្ឋមួយក្រុមដែលមានគ្នាប្រាំមួយនាក់ បានធ្វើការរារាំងមនុស្សមួយចំនួនដែលរស់នៅក្នុងឃុំនោះពីការបោះឆ្នោត ដោយអ្នកទាំងនោះ ត្រូវបានគេសង្ស័យថាជាជនជាតិវៀតណាម។ អាជ្ញាធរដែនដី នៅទីនោះពុំបានចាត់ការអ្វីទាល់តែសោះ ដើម្បីការពារសិទ្ធិបោះឆ្នោតរបស់ ពលរដ្ឋទាំងនោះ។ អ្នកជិតខាងម្នាក់របស់បុរសម្នាក់ដែលត្រូវបានគេរារាំងមិនឲ្យបោះឆ្នោតនោះ បានអះអាងថា ជននេះបានរស់នៅក្នុងភូមិនេះជាយូរយារណាស់មកហើយ។ ប្រជាពលរដ្ឋក្នុងឃុំនេះ បានអះអាងថាពួកគេ កំពុងរារាំងមនុស្សមួយចំនួនមិនឲ្យបោះឆ្នោត ដោយសារជាតិសាសន៍មិនមែនរបស់អ្នកទាំងនោះប៉ុណ្ណោះ។

ការបដិសេធសិទ្ធិបោះឆ្នោត ដោយពាក់ព័ន្ធនឹងជាតិសាសន៍មិនមែនខ្មែរ ដែលត្រូវបានធ្វើឡើងដោយប្រជាពលរដ្ឋក្នុងឃុំបែបនេះ គឺត្រូវបានកត់សម្គាល់ នៅក្នុងការិយាល័យបោះឆ្នោតផ្សេងទៀតផងដែរ រួមមានសាលារៀនមួយ ក្នុងសង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ និងនៅក្នុងឃុំខ្ពបអាទាវ ស្រុកលើកដែក ខេត្តកណ្តាល។ បញ្ហាបែបនេះជាការរំលោភលើកតព្វកិច្ចសិទ្ធិមនុស្សកម្ពុជាហើយត្រូវតែមានការស៊ើបអង្កេតឲ្យបានត្រឹមត្រូវ។ ប៉ុន្តែការស៊ើបអង្កេតបែបនេះ ក៏ត្រូវលើកយកមកពិចារណា និងចងក្រងជាឯកសារផងដែរ អំពីការប្រើប្រាស់ឯកសារក្លែងក្លាយជាទូទៅ សម្រាប់បន្លំក្នុងការបោះឆ្នោត ដូចដែលបានធ្វើការកត់សម្គាល់នៅក្នុងរបាយការណ៍នេះ។

## ខេត្តកំពង់ចាម

នៅល្ងាចមុនថ្ងៃបោះឆ្នោត មេបញ្ជាការនគរបាល នៅខេត្តកំពង់ចាម បានមកដល់ផ្ទះ ដែលបុគ្គលិកអង្គការ លីកាដូ ពីរនាក់ (ម្នាក់ជាជនបរទេស និង ម្នាក់ជាជនជាតិខ្មែរ) កំពុងសំរាកនៅទីនោះ ១ថ្ងៃមុនពេលទៅធ្វើការសង្កេតការណ៍នៅថ្ងៃបោះឆ្នោត។ បុគ្គលិកជនជាតិខ្មែរត្រូវបានសាកសួរយ៉ាងលំអិតថាហេតុអ្វីបានជានាំជនបរទេសមកខេត្តនេះ ដោយគ្មានការអនុញ្ញាតពីមេភូមិជាមុន។ បន្ទាប់មកមេនគរបាលនោះក៏បានសួរជនបរទេសថា តើគាត់ចេះជក់បារី ឬ ផឹកស្រាឬទេ។ ពេលសួរថា ហេតុអ្វីបានជាសួរសំណួរបែបនេះ មេនគរបាលនោះបាននិយាយថា ទីប្រឹក្សាជនជាតិបរទេសនោះអាចជាអ្នកចែកចាយគ្រឿងញៀន។ ស្រាប់តែមេនគរបាលនោះ ក៏បានចាកចេញទៅ ហើយក៏គ្មានបញ្ហាកើតឡើងទៀតដែរ ជាមួយនឹងការសង្កេតការណ៍បោះឆ្នោតថ្ងៃបន្ទាប់នោះ។

នៅកំពង់ចាមនេះផងដែរ ប្រធាន និងអនុប្រធាន នៅការិយាល័យបោះឆ្នោតលេខ ០៧៨៧ ក្នុងឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ត្រូវបានគេរាយការណ៍មកថា បានគំរាមកំហែងអ្នកភូមិថា ត្រូវតែបោះឆ្នោតឲ្យគណបក្សប្រជាជន។ មន្ត្រីនោះ បានធ្វើការគូសចំណាំតូចមួយនៅលើសន្លឹកឆ្នោត ដើម្បីចង់ដឹងថា តើគេបោះឲ្យគណបក្សកាន់អំណាច ឬ អត់។ បន្ទាប់មកសមាជិករបស់គណបក្សកាន់អំណាចបានចែកអំណោយជាកញ្ចប់តូចៗ ឲ្យប្រជាពលរដ្ឋណាដែលបោះឆ្នោតឲ្យគណបក្សកាន់អំណាច។

## ឃុំតាកុង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

អ្នកសង្កេតការណ៍បានកត់សម្គាល់ឃើញថា មេភូមិឈ្មោះ ឈឿន ឆាន់ បានដើរជុំវិញទីធ្លា នៃការិយាល័យបោះឆ្នោតលេខ ០៩១៩ ព្រមទាំងបានផ្តល់មធ្យោបាយធ្វើដំណើរដល់ប្រជាពលរដ្ឋដែលទៅបោះឆ្នោតទៀតផង។ ក្នុងពេលនោះដែរ ប្រពន្ធរបស់គាត់ក៏បានអង្គុយខាងក្រៅការិយាល័យបោះឆ្នោត ដើម្បីប្រាប់ប្រជាពលរដ្ឋឲ្យបោះឆ្នោតឲ្យគណបក្សប្រជាជន។ អ្នកភូមិបានរអ៊ូរទាំអំពីរឿងនោះថា ជាការបំភិតបំភ័យដោយវត្តមានរបស់អាជ្ញាធរភូមិ និងដោយមន្ត្រីនគរបាលដែលដើរចុះឡើងជុំវិញមណ្ឌលនោះ។

## ការគំរាមកំហែងដោយវត្តមាន របស់អាជ្ញាធរក្នុងតំបន់ និងមន្ត្រីគណបក្សមួយចំនួន

នៅតាមតំបន់ជាច្រើន អ្នកសង្កេតការណ៍ត្រូវបានរាយការណ៍ដោយក្រុមអ្នកភូមិថា អ្នកទាំងនោះមានអារម្មណ៍ថា ត្រូវបានគំរាមកំហែងដោយវត្តមានរបស់អាជ្ញាធរមូលដ្ឋាន សមាជិកគណបក្សនៅក្នុងមណ្ឌលបោះឆ្នោត។ ឧទាហរណ៍ នៅមណ្ឌលបោះឆ្នោតវិទ្យាល័យព្រៃថ្នង ការិយាល័យលេខ ៤០៦៥ ស្រុកទឹកឈូ ខេត្តកំពត អ្នកបោះឆ្នោត មួយចំនួនបាន បង្ហាញអារម្មណ៍ថា ត្រូវបានគំរាមកំហែងដោយវត្តមានមេភូមិ នៅក្នុងការិយាល័យបោះឆ្នោត។ ដូចគ្នានេះដែរ នៅឃុំឃ្លាំងមាសក្នុងខេត្តបាត់ដំបង អ្នកសង្កេតការណ៍ បានរាយការណ៍មកថា សមាជិកគណបក្សកាន់អំណាចឈរចំងាយប្រហែល១៥០ម៉ែត្រពីបន្ទប់បោះឆ្នោត និងចាំកត់ឈ្មោះប្រជាពលរដ្ឋ។

## យោបល់មួយចំនួន

ព្រឹត្តិការណ៍ដែលបានពិពណ៌នានៅក្នុងរបាយការណ៍នេះ ត្រូវបានប្រមូលដោយអ្នកសង្កេតការណ៍អង្គការ លីកាដូ ដែលបានធ្វើការសង្កេតការណ៍នៅតាមការិយាល័យបោះឆ្នោតជាង ១០០ ការិយាល័យ ដោយចំណាយពេលពីរឬបីម៉ោងសម្រាប់ការិយាល័យនីមួយៗនៅក្នុងថ្ងៃបោះឆ្នោត។ ពួកគេបានបង្ហាញនូវចំនុចជាបញ្ហាមួយចំនួនអំពីចេតនាបន្លំនៅក្នុងបញ្ជីឈ្មោះ និងក្លែងឯកសារមួយចំនួនក៏ដូចជា បញ្ហាមិនប្រក្រតីជាច្រើនទៀតផងដែរ។ ដូចនេះ អង្គការ លីកាដូ សូមផ្តល់យោបល់មួយចំនួនដូចខាងក្រោម៖

►►► លក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីឈ្មោះបោះឆ្នោត និងការរក្សាការធ្វើបច្ចុប្បន្នភាពនៃបញ្ជីឈ្មោះ ត្រូវបានទទួលស្គាល់ថាមិនអាចអនុវត្តទៅបានដោយមានប្រសិទ្ធិភាព និងជឿ

ជាក់បាន។ មិនមានភាពត្រឹមត្រូវស្របច្បាប់ទាល់តែសោះ ដែលចំនួនប្រជាពលរដ្ឋចុះឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតច្រើនជាង ១០០ភាគរយ អត្រានៃអ្នកបាត់ឈ្មោះបោះឆ្នោតមានកម្រិតខ្ពស់ហួសពីការរំពឹងទុក ឬ ភាគរយខ្ពស់នៃការមានឈ្មោះស្ទួនទូទាំងប្រទេស។ ដំណើរការបច្ចុប្បន្ន ត្រូវតែធ្វើការពិនិត្យ ហើយយន្តការផ្សេងមួយ ដូចជាប័ណ្ណសំគាល់ខ្លួនដែលត្រូវបានប្រើប្រាស់កាលពីការបោះឆ្នោត ឆ្នាំ១៩៩៣ គួរតែត្រូវបានពិចារណា។ ជាឧទាហរណ៍ ប័ណ្ណសំគាល់ខ្លួនបែបនេះ បានធ្វើឡើងយ៉ាងមានប្រសិទ្ធិភាពនៅក្នុងប្រទេសដទៃ ហើយត្រូវបានណែនាំដោយអ្នកជំនាញការណ៍បោះឆ្នោត។

►►► គណកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាធម្មនុញ្ញ គួរតែត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញ ដើម្បីធានាថាស្ថាប័នទាំងពីរមានភាពឯករាជ្យមិនលំអៀងពីគណបក្សនយោបាយ។

►►► ត្រូវមានការរាប់សន្លឹកឆ្នោតឡើងវិញ ដោយផ្អែកតាមទម្រង់១១០២ ជាផ្លូវការនៅតាម ការិយាល័យបោះឆ្នោតដោយមានវត្តមានអ្នកសង្កេតការណ៍។ ការរាប់សន្លឹកឆ្នោត គួរតែត្រូវបានធ្វើឡើងវិញនៅតាមខេត្តដែលមានការប្រកួតប្រជែងខ្លាំង។

►►► ត្រូវមានការស៊ើបអង្កេតដែលមានលក្ខណៈឯករាជ្យ និងស្មោះត្រង់ពិតៗអំពីភាពមិនត្រឹមត្រូវ។

►►► រៀបចំបោះឆ្នោតឡើងវិញ នៅការិយាល័យណាដែលមានការអំពាវនាវសុំ ឬ ចាំបាច់

►►► ទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោតទាំងនោះ (ប័ណ្ណខៀវ) គឺងាយរងការរំលោភណាស់ ហើយហាក់ដូចជាបានបម្រើប្រយោជន៍តិចតួចបំផុត។ គ្រប់គ្នា គួរតែអាចទទួលបាននូវឯកសារណាមួយក្នុងចំណោមឯកសារជាច្រើន ដែលបញ្ជាក់អត្តសញ្ញាណជាផ្លូវការ ហើយដែលត្រូវអនុញ្ញាតិដោយ ស្របតាមលក្ខខណ្ឌតម្រូវនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

►►► នីតិវិធីទាំងឡាយដែលតម្រូវក្នុងការបង្កើតការិយាល័យបោះឆ្នោតថ្មីៗត្រូវតែពិនិត្យកែតម្រូវឡើងវិញ ហើយកិច្ចការពារត្រូវតែមានដើម្បីទប់ស្កាត់មណ្ឌលថ្មី ដើម្បីការពារពីការប្រើប្រាស់ក្នុងការបន្លំលទ្ធផល។ ក្នុងករណីដែលការិយាល័យបោះឆ្នោតណាមួយត្រូវបានបង្កើតឡើងត្រឹមត្រូវក្នុងគោលបំណងសម្រាប់តែអង្គភាពកងទ័ពប៉ុណ្ណោះនោះ ត្រូវតែមានវិធានការណ៍ ការពារដើម្បីការពារការសម្ងាត់របស់អ្នកបោះឆ្នោត។

www.licadho-cambodia.org